**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

## និក្ខេបបទ

# ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា
# ករណីសិក្សា៖សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

# The situation of Training Pre-school Teacher
# Cased Study: Pre-SchoolTeacher Training Center


**ដោយ**/by

**ឈន ឈាង**

**CHHON CHHEANG**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិ នៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា
# ករណីសិក្សា៖សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

## The situation of Training Pre-school Teacher

## Cased Study: Pre-SchoolTeacher Training Center

ដោយ/by

**ឆន ឈាង**

**CHHON CHHEANG**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

**សាស្ត្រាចារ្យជំនួយ ៖ សាស្ត្រាចារ្យ ម៉ែន សុខសុន្ទី**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិ នៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៧២៩ **អយក.**
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# មាតិកា

ទំព័រ


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ....................................................................................3

លិខិតបញ្ជាក់ ...............................................................................................................4

សេចក្តីថ្លែងអំណរគុណ ....................................................................................................5

មូលន័យសង្ខេប ............................................................................................................7

ABSTRACT .................................................................................................................9

ជំពូកទី១ ....................................................................................................................11

១សេចក្តីផ្តើម ...............................................................................................................11

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ......................................................................................11

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...................................................................................14

១.៣. គោលបំណងនៃការស្រាវជ្រាវ ......................................................................................15

១.៤. សំណួរនៃការស្រាវជ្រាវ ..............................................................................................15

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ......................................................................................15

១.៦. វិសាលភាពនៃការស្រាវជ្រាវ ........................................................................................16

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖ .....................................................................................16

១.៨. កម្មវិធីនៃការស្រាវជ្រាវ .............................................................................................17

ជំពូកទី២ ....................................................................................................................19

២រំលឹកទ្រឹស្តី. ...............................................................................................................19

២.១. ពាក្យគន្លឹះ ...........................................................................................................19

២.២. និយន័យ .............................................................................................................19

ជំពូកទី៣ ....................................................................................................................36

៣វិធីសាស្ត្រស្រាវជ្រាវ. ......................................................................................................36

៣.១. ប្រភពឯកសារ ........................................................................................................36

៣.២. ការជ្រើសរើសភាគសំណាក ........................................................................................36

៣.៣. ឧបករណ៍ស្រាវជ្រាវ .................................................................................................36

៣.៤. ការប្រមូលទិន្នន័យ ........................................................................................ 37

៣ការវិភាគទិន្នន័យ ៥. ........................................................................................ 38

ជំពូកទី៤ ........................................................................................................ 40

៤លទ្ធផលស្រាវជ្រាវ . ........................................................................................ 40

៤១.. លទ្ធផល ...................................................................................................... 40

ជំពូកទី៥ ........................................................................................................ 60

៥សេចក្តីសន្និដ្ឋាននិងអនុសាសន៍ . ........................................................................ 60

៥.១. សេចក្តីសន្និដ្ឋាន ............................................................................................ 60

៥.២. អនុសាសន៍ ..................................................................................................... 61

ឯកសារយោង ..................................................................................................... 62

ឧបសម្ព័ន្ធ ........................................................................................................ 64

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា“ **ស្ថានភាព នៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម** ដើម្បីបំពេញឱ្យលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ប្រធានបទនេះពុំទាន់ត្រូវបានជ្រើសរើស ដោយអ្នកសិក្សាស្រាវជ្រាវណាម្នាក់ដើម្បីបំពេញលក្ខខណ្ឌសិក្សារបស់ខ្លួន សម្រាប់ទទួលយកសញ្ញាបត្រនៅវិទ្យាស្ថាននេះ វិទ្យាស្ថានថ្នាក់ស្មើណាមួយ ឬ សាកលវិទ្យាល័យណា ដទៃទៀតនៅឡើយទេ។ រាល់ខ្លឹមសារនៃ សេចក្តីដកស្រង់ឬការធ្វើបំណកស្រាយ(Paraphrase)នានាត្រូវបានបញ្ជាក់អំពី ឈ្មោះអត្ថបទ ឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទច្បាស់លាស់ ពីប្រភពឯកសារដើម។

ខ្ញុំបាទសូមអះអាងយ៉ាងឱឡារិកថា ស្នាដៃនៃការសិក្សាស្រាវជ្រាវនេះ ពិតជាបានសិក្សាស្រាវជ្រាវដោយរូបខ្ញុំបាទយ៉ាងពិតប្រាកដ។

ថ្ងៃសៅរ៍ ៣រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ឆន ឈាង**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ជាសាស្ត្រាចារ្យដឹកនាំ

លោក ម៉ែន សុខសុន្ធី ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក ឆន ឈាង ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាករណីសិក្សាៈសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**" ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៣រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩

............................................ ............................................

| | |
|---|---|
| ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | លោក ម៉ែន សុខសុន្ធី |
| នាយកវិទ្យាស្ថានជាតិអប់រំ | សាស្រា ទចារ្យនៃវិទ្យាស្ថានជាតិអប់រំ |

# សេចក្តីថ្លែងអំណរគុណ

ទូលព្រះបង្គំខ្ញុំម្ចាស់ខ្ញុំព្រះករុណាខ្ញុំបាទ ឆន ឈាង ជានិស្សិត “បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ”ជំនាន់ទី៦ សូមលំឱនកាយវាចាសម្តែងនូវគារវភក្តី ការគោរពចំពោះ៖

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គទ្រង់ បានចំណាយព្រះកាយថាមពលនិងពេលវេលា ដោយមិនគិតពីសេចក្តីនឿយហត់ ឬព្រះកាយមានប្រឈួនឡើយ ឱហាតបំពេញព្រះរាជកិច្ចតាមព្រះរាជតួនាទី ដែលច្បាប់រដ្ឋកំណត់ថ្វាយ ប្រកបដោយទសពិធរាជធម៌ ជាទីគោរពកោតស្ញប់ស្ញែងក្រៃលែងពន់ពេក បច្ច័យនេះគឺក៏ដើម្បីជាម្លប់ផ្តល់នូវសេចក្តីសុខចម្រើននិងសុភមង្គល សម្រាប់ប្រជានុរាស្ត្រ និងព្រះរាជវង្សានុវង្សទាំងឡាយ នៃព្រះអង្គ ទូទាំងព្រះរាជាណាចក្រកម្ពុជាយើងទាំងមូលនេះ។

ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវចក្ខុវិស័យ គោលដៅអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ ដែលមានដំណាក់កាលនីមួយៗច្បាស់លាស់ សម្រាប់ប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ឱ្យមានការរីកចម្រើនជាលំដាប់ លើគ្រប់ផ្នែក ដូចជា: ការផ្តល់ឱ្យមានជំនឿទុកចិត្តពីអ្នកវិនិយោគទាំងឡាយ ដែលហ៊ានធ្វើការសម្រេចចិត្តបោះទុនរកស៊ី នៅព្រះរាជាណាចក្រកម្ពុជា និងបានផ្តល់ការងារជាច្រើនដល់ប្រជាពលរដ្ឋយើង ឱ្យទទួលបានប្រាក់ចំណូល សម្រាប់បង្កើនសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ជាងនេះទៀតប្រទេសជាតិ ក៏ទទួលបានផលកម្រៃពីការវិនិយោគនេះ ដើម្បីអភិវឌ្ឍវិស័យនានាជាច្រើនដែរ។ ការរីកចម្រើនទាំងនេះកើតមានបាន ក៏អាស្រ័យដោយរាជរដ្ឋាភិបាល ខិតខំបញ្ចុះបញ្ចូលឱ្យអ្នកវិនិយោគមកធ្វើការរកស៊ីនៅកម្ពុជា និងការរក្សាបាននូវសុខសន្តិភាពដ៏ល្អសម្រាប់ប្រទេសជាតិយ៉ាងពិតប្រាកដ ដែលជាបច្ច័យល្អដល់វិស័យអប់រំ។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ជាញឹកញាប់ លើច្រើនចំណុចតាមដំណាក់កាលនីយួយៗ ដើម្បីបម្រើឱ្យគោលនយោបាយរបស់វិស័យអប់រំ និងឆ្លើយតបទៅនឹងគោលដៅអប់រំជាតិ។ ជាពិសេសក្នុងអាណត្តិរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ**ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានេះ ដែលបានកំណត់នូវចំណុចកំណែទម្រង់ច្បស់លាស់និងចំៗបញ្ហាដោយដំណាក់កាលទី១មានប្រាំបីចំណុច និងដំណាក់កាលទី២កើនដល់១៥ចំណុច ឈរលើសសរស្តម្ភប្រាំជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់ផ្នែកក្នុងប្រព័ន្ធអប់រំធ្វើការប្រតិបត្តិ។ ម្យ៉ាងវិញទៀតការនៅបន្តឱ្យមាននូវកម្មវិធីបណ្តុះបណ្តាលបញ្ញាបត្រជាន់ខ្ពស់ ដែល សហការគាំទ្រពីអង្គការ CIESF ( Cambodia International Education Support Foundation) ជាមួយវិទ្យាស្ថានជាតិអប់រំក៏ជាចំណែកមួយ

ដើម្បីឆ្លើយតបនឹងគោលនយោបាយទាំងពីរ របស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ ហើយដែលផ្តល់ឱកាសដល់ យើងខ្ញុំបានបង្កើននូវសមត្ថភាព យល់ដឹងកាន់តែស៊ីជម្រៅ អំពីការគ្រប់គ្រងអប់រំ។

លោកគ្រូ អ្នកគ្រូទាំងអស់ចាប់ពីបឋមសិក្សាដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះដែលបានបង្ហាត់បង្រៀនផ្តល់នូវ ចំណេះអក្ខរៈ នព្វន្ត ជំនាញផ្សេងៗ និងការទូន្មានប្រៀន ប្រដៅអំពីសីលធម៌ សុជីវធម៌ សម្រាប់ជីវិតរស់នៅឱ្យល្អប្រពៃ និងធ្វើអ្វីៗ ដើម្បីបម្រើផលប្រយោជន៍ដល់សង្គមជាតិយើង។ ជាសំខាន់ដោយឡែក ឯកឧត្តម បណ្ឌិតសាស្ត្រាចារ្យ **សៀង សុវណ្ណា** ជាសាស្ត្រាចារ្យដឹកនាំផ្ទាល់របស់ខ្ញុំ ដែល បានលះបង់ពេលវេលាដ៏មានតម្លៃ និងផ្តល់នូវយោបល់ណែនាំល្អៗ សម្រាប់ការសរសេរនិក្ខេបបទបានសម្រេចដូច្នេះ។

ជាពិសេសវិសាលទៀតនោះ អ្នកមានគុណទាំងសងខាង គឺអ្នកម្តាយបង្កើតរបស់ខ្ញុំ និងលោកឪពុកនិងអ្នកម្តាយក្មេក ជាទីគោរពដ៏ខ្ពង់ខ្ពស់នៃខ្ញុំ ភរិយាសំឡាញ់ដែលតែងតែលើកទឹកចិត្ត និង គាំទ្រគ្រប់ពេលវេលា បងប្អូនបង្កើតនិងបងប្អូនថ្លៃជាទីស្រឡាញ់ទាំងអស់ដែលតែងតែគោរពស្រឡាញ់និងផ្តល់ភាពកក់ក្តៅចំពោះខ្ញុំ។

## កតញ្ញុតាកថា

ខ្ញុំសូមវន្ទា អ្នកម្តាយពុំងា បង្កើតនៃខ្ញុំ
ឪពុកម្តាយក្មេក សុទ្ធតែឧត្តម ដែលបានអប់រំ
ឱ្យកូនបានល្អ។
អរគុណភរិយា គ្រប់ពេលវេលា តែងជួយគាំទ្រ
ញាតិមិត្តជិតស្និទ ចិត្តពិតស្មោះសរ ជួយគ្នាគ្រាក្រ
សូមកើនធនធាន ។
អរគុណចំពោះ គរុទាំងអស់ ដែលបានបង្រៀន
មកដល់រូបខ្ញុំ ឱ្យបានកើតមាន ចំណេះជាយាន
ដឹកនាំជីវិត។

លោកនាយក នាយិការង លោកគ្រូ អ្នកគ្រូ និងនិស្សិតឆ្នាំទី១ ឆ្នាំសិក្សា២០១៨-១៩ នៃសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈិមទាំងអស់ ដែលបានជួយផ្តល់ទិន្នន័យតាមកម្រងសំណួរសម្ភាសន៍ របស់ខ្ញុំបាទ ។ សូមសេចក្តីសុខចម្រើន កើតឡើងដោយភាពសុចរិតយុត្តិធម៌ ផ្តល់នូវគុណតម្លៃដ៏ឧត្តុង្គឧត្តមចំពោះ ប្រជាពលរដ្ឋគ្រប់ៗរូប និងសង្គមខ្មែរយើងទាំងមូល ជានិច្ចនិរន្តរ៍កុំបីរំលងមួយវេលាណាឡើយ។

# មូលន័យសង្ខេប

ការអប់រំជាគន្លឹះសំខាន់បំផុត សម្រាប់កសាងធនធានមនុស្ស បម្រើឱ្យប្រទេសជាតិ ដែលធនធានទាំងនោះផ្ដើមកសាងនិងអភិវឌ្ឍបុគ្គលខ្លួនឯងឱ្យបានល្អជាមុន បន្ទាប់មកទៀតគឺក្រុមគ្រួសារ និងឈានទៅប្រទេសជាតិ ដើម្បីជំរុញសេដ្ឋកិច្ចឱ្យរីកចម្រើន ប្រទេសមានការអភិវឌ្ឍ ទទួលបានភាពកោតសរសើរស្ញប់ស្ញែង និងគុណតម្លៃពីអន្តរជាតិ។

ស្ថាបត្យករ នៃការកសាងធនធានមនុស្ស គឺជាគ្រូបង្រៀនគ្រប់កម្រិតថ្នាក់ ហើយដែលអ្នកកសាងមូលដ្ឋានគ្រឹះ នៃអ្នកសិក្សាមុនដំបូងគេបង្អស់ គឺជាគ្រូមត្តេយ្យសិក្សា។ គ្រូមត្តេយ្យសិក្សា ត្រូវបានបណ្ដុះបណ្ដាលយ៉ាងពិសេសជាងគេ ដែលអ្នកផងទាំងឡាយមិនសូវមានអ្នកយល់ដឹង ពីការងាររបស់គ្រូមត្តេយ្យសិក្សាឡើយ។ ដោយមានពេលខ្លះអ្នកមិនបានយល់ដឹងពីការងារគ្រូមត្តេយ្យសិក្សាទាំងនោះ ធ្វើដូចជាខ្លួនឯងយល់ដឹងជាងគ្រូមត្តេយ្យសិក្សាទៅវិញ ហើយបានលើកឡើងនូវគំនិតផ្សេងៗ តាមតែការរើរវាយរបស់ខ្លួន លើការអប់រំកុមារមត្តេយ្យសិក្សា។ យ៉ាងដូច្នេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវផ្ដោតលើស្ថានភាព នៃការបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សាមត្តេយ្យមជ្ឈិម ដើម្បីស្វែងយល់ពីការងារដឹកនាំនិងគ្រប់គ្រង របស់នាយកសាលាចំពោះការកសាងធនធានមនុស្ស នៅក្នុងសាលាមួយនេះ ថាតើមានកត្តាលីករអ្វីខ្លះដែលជំរុញឱ្យមានការអភិវឌ្ឍល្អប្រសើរ និងមានកត្តាអ្វីខ្លះដែលជាឧបសគ្គរាំងស្ទះ ដល់ការរីកចម្រើនលូតលាស់របស់សាលា។ ភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវ បានធ្វើការសិក្សាស្វែងយល់ គឺមានគណៈគ្រប់គ្រងនិងគ្រូឧទ្ទេសចំនួន១៤នាក់ និងគរុសិស្សជំនាន់ទី៣២ ឆ្នាំទី១ នៃឆ្នាំសិក្សា២០១៨ –២០១៩ ចំនួន១៨៣នាក់។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញដូចខាងក្រោម៖

– គណៈគ្រប់គ្រងនិងគ្រូឧទ្ទេសនៃសាលាគរុកោសល្យមធ្យមសិក្សាមត្តេយ្យមជ្ឈិម ភាគច្រើន មានសមត្ថភាពអាចប្រើប្រាស់កុំព្យូទ័រកម្មវិធីWord បាន ៦៨.៣% Excel ២២.៤% និង power point៩.៣%។ ចំណែកឯការប្រើប្រាស់ភាសាបរទេស អាចធ្វើការស្វែងរកព័ត៌មានបានក្នុងកម្រិតសមស្រប សម្រាប់ការបង្រៀនរបស់ខ្លួន។

– គ្រូឧទ្ទេសមាន បរិញ្ញាបត្រជាន់ខ្ពស់ និងនៅមានអ្នកមានសញ្ញាបត្រកម្រិតក្រោមបរិញ្ញាបត្រខ្លះ ហើយការបង្រៀន មានប្រើវិធីសាស្ត្របង្រៀនថ្មីៗដែរ។

– កម្មវិធីបណ្តុះបណ្តាលដល់គរុសិស្ស មានភាពគ្រប់ដណ្តប់គ្រប់ជ្រុងជ្រោយល្អ និងលទ្ធផលសិក្សារបស់គរុសិស្សបានល្អ។

– ការដឹកនាំនិងគ្រប់គ្រងរបស់នាយក បានអនុវត្តឆ្លើយតបនឹងចំណុចភាគច្រើន នៃស្តង់ដានាយកសាលា ដូចជា ការបង្កើតនូវចក្ខុវិស័យ បេសកម្ម ការកសាងផែនការ ការធ្វើបំណែងចែកភារកិច្ចដល់បុគ្គលិក ការលើកទឹកចិត្ត និងការពិនិត្យតាមដានការអនុវត្តការងាររបស់បុគ្គលិក ជាដើម។

– ចំពោះការស្នាក់នៅរបស់គរុសិស្សក្នុងអន្តេវាសិកដ្ឋានវិញ មានការគ្រប់គ្រងបានល្អ រក្សាបាននូវសុវត្ថិភាព និងគោរពពេលវេលានៃការសិក្សាបានប្រសើរ។ មានគរុសិស្សមួយចំនួន មានការស្នាក់នៅខាងក្រៅ ព្រោះថាអន្តេវាសិកដ្ឋានមិនអាចទទួល គរុសិស្សឱ្យស្នាក់នៅខាងក្នុងបានទាំងអស់គ្នាឡើយ។

លទ្ធផលនេះបញ្ជាក់ឱ្យឃើញថា ទោះបីមានចំណុចខ្សោយខ្លះក៏ពិតមែន តែសាលាត្រូវតែធ្វើឱ្យមាននវានុវត្តន៍ជានិរន្តរ៍ នោះគឺទាមទារធ្វើវិក្រឹតការលើគុណវុឌ្ឍិគ្រូឧទ្ទេសជាប្រចាំឬជួយគាំទ្រ ដល់ការបន្តបង្កើនសមត្ថភាពបន្ថែមចំពោះពួកគាត់ ជាពិសេសគ្រូឧទ្ទេសដែលស្ថិតក្រោមកម្រិតបរិញ្ញាបត្រ។ ការបង្រៀនមិនត្រូវឯកទ្ទេស ជាប្រការត្រូវពិចារណាជាចម្បងផងដែរ ថាតើត្រូវធ្វើយ៉ាងណា ដោយរបៀបណា ជាមួយអ្នកណា។ ចំពោះអន្តេវាសិកដ្ឋានគួរពង្រីកបន្ថែម សម្ភារៈបង្រៀននិងរៀន រួមនិងសម្ភារៈរូបវន្តផ្សេងៗទៀតក៏គួរស្វែងរកថវិកាពីប្រភពផ្សេងៗ តាមដែលអាចស្វែងរកបាន ដើម្បីបង្កើនសក្តានុពលក្នុងការអនុវត្តការងារ ទទួលបានគុណផលខ្ពស់ ។

# ABSTRACT

Education is the most important key for building human resource to do service of the country that human resources have to starting good with theirselves development first then with their families and next step for their own country. To help the country's economy growing better and the country will be appreciated.

Architect of building human resource is teacher. The first teacher is preschool teacher who builds the basic knowledge to children. Preschool teacher is trained essentail technique that most of people do not know about those tichniques. Some time peopl who do not know about how to educate small children try to say somethings is not suitable for children act. It is just thinking by them those are right and tell to the preschool teacher. So that why researcher haveto do reseach on the situation of Pre-school Teacher Training Center and researcher want to understand about pre-school director's management and leadship. The sample of research is 14 pre-school director vice director and pre-school trainers and 183 inservice teachers' year 1 academic year 2018-2019. The result of the research as below:

−Pre-school director vice director and pre-school trainers can use computer program Word 68.3% Excel 22.4% and Power point 9.3% and foriegn language can use for doing research something that they want.

−The trainer's Qualification some trainers have bachelor degrees, some trainers have master degrees and some trainers have under bachelor degrees.

−There is good curriculum for training inservice teacher and the result of teacher student is good.

−The management and leadership of director, it responds to most points of director's standard points. Such as: visoin, mission, action plan job discription are developed, monitered and also did staff's encouragement.

−Teacher students who living in dormitory is good condition, safe and got better result. But some teacher students are still living out side dormitory becoase the room in dormitory is not enough for all.

These results show that pre-school teacher training center has develeped better but to keeping sustainable inovation. Pre-school teacher training centerhas to improve trainers' qualification esspecially for the trainers who are under bachelor degree. Fortrainers who teach beside their subject also have to consider in advance. And dormitory should expand, teaching and learning materials to enhanc implementation get high quality of results.

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

## ១.សេចក្ដីផ្ដើម

### ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

អាណត្តិនៃការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានបញ្ចប់កាលពីឆ្នាំ២០១៥ ដែលបានឯកភាពគ្នា ក្នុងសន្និសីទអប់រំពិភពលោកនាទីក្រុងដាកា ប្រទេសសេណេហ្គាល់ទ្វីបអាហ្វ្រិកនៅឆ្នាំ២០០០ ដែលមានគោលបំណង ឱ្យកុមារនិងយុវជនសម្រេចនូវ តម្រូវការរៀនសូត្រទាំងអស់គ្នា ត្រឹមឆ្នាំ២០១៥ និងជាមួយគ្នានោះដែរ បានកំណត់បាននូវគោលដៅអភិវឌ្ឍសហសវត្សចំនួន៨ រួមមាន៖ (១)លុបបំបាត់ចោលនូវភាពអត់ឃ្លាននិងភាពក្រីក្រដ៏អាក្រក់ (២)សម្រេចការអប់រំជាសាកល (៣)លើកស្ទួយយេនឌ័រនិងផ្តល់អំណាចដល់ស្ត្រី (៤)កាត់បន្ថយមរណភាពកុមារ ( ៥)បង្កើនតំហែទាំសុខភាពមាតា (៦)ប្រឆាំមេរោគហ៊ីវ ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត (៧)ធ្វើឱ្យបរិស្ថានភាពនិរន្តរភាព (៨)ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ*(ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០, ក្រសួងអយក. ខែកុម្ភៈ ឆ្នាំ២០១៩)*។ ទោះបីការអប់រំសម្រាប់ទាំងអស់គ្នា បានបញ្ចប់មែនពិត តែលទ្ធផលនៃគោលដៅទី២ សម្រេចការអប់រំជាសកល មិនទទួលបានលទ្ធផលជោគជ័យ តាមអ្វីដែលប្រទេសនីមួយៗ ប្តេជ្ញាចិត្តនៅពេលមុនអនុវត្តនោះទេ។

ស្ថិតក្នុងដំណាក់កាលនេះ គឺជាអាណត្តិនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ហើយដែលបានប្រកាសនៅទីក្រុងអ៊ីនឈុន(Incheon)ប្រទេសកូរ៉េខាងត្បូង។ មានប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ជាង១៣០ប្រទេសបានចូលរួម កាលពីខែឧសភា ឆ្នាំ១០១៥ ដែលមានរយៈពេលសម្រាប់អនុវត្តចំនួន១៥ឆ្នាំ គឺដល់ឆ្នាំ២០៣០។ គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាពរួមមាន គោលដៅចំនួន១៧ ក្នុងនោះការអប់រំស្ថិតនៅគោលដៅទី៤ដែលបញ្ជាក់ថា ធ្វើឱ្យប្រាកដនូវការអប់រំ ដែលមានគុណភាព សមធម៌ បរិយាប័ន្ន និងផ្តល់ឱកាសសិក្សារៀនសូត្រពេញមួយជីវិតសម្រាប់គ្រប់ៗគ្នា។

បើផ្អែកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់រដ្ឋត្រង់ជំពូកទី៦ អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច នៅមាត្រា៦៥. ~ មាត្រា៦៦.~ មាត្រា៦៧.~ និងមាត្រា៦៨.~ គឺបញ្ជាក់ពីតួនាទីរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ លើការផ្តល់ចំណេះដឹងជំនាញ ការអប់រំកាយនិងកីឡា ដើម្បីសុខមាលភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។

វិស័យអាទិភាព៤នៃយុទ្ធសាស្ត្រចតុកោណ ដែលរាជរដ្ឋាភិបាលអនុវត្តកន្លងមក គឺ ផ្លូវ ទឹក ភ្លើង និងមនុស្ស។ នៅក្នុងដំណាក់កាលទី១និងទី២ រាជរដ្ឋាភិបាលបានផ្តល់អាទិភាព លើការកសាងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវថ្នល់។ តែចាប់ពីដំណាក់កាលទី៣ រហូត មកដល់ដំណាក់កាលទី៤ នៃនីតិកាលទី៦នេះ គឺ "មនុស្ស"ជាអាទិភាពស្ថិតនៅមុំទី១ នៃ យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលពោលគឺ ផ្តោតលើការអភិវឌ្ឍធនធាន មនុស្ស ដែលរួមមាន៤ចំណុចតូចៗទៀត ហើយចំណុចទី១ គឺ ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលទាក់ទងនឹងបរិបទរបស់យើង ។ ការអនុវត្តកម្មវិធី នយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាសំដៅឆ្លើយតបទៅនឹង គោលដៅ នៃចក្ខុវិស័យ របស់រាជរដ្ឋាភិបាលកម្ពុជាគឺ ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេស ដែល មាន ចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ២០៣០និងចំណូលខ្ពស់ នៅឆ្នាំ២០៥០ *(ឯកសារយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤)*។ ការកំណត់ចក្ខុវិស័យដូច្នេះ ដោយសាររាជរដ្ឋាភិបាលរំពឹងលើ វិស័យអប់រំដែលជាវិស័យផលិតធនធានមនុស្ស ដែលធ្វើយ៉ាងឱ្យផលិតផលទទួលបាន គឺ ជាយុវជនមានសមត្ថភាព ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា បម្រើការងារផលិតបានផលិតផលខ្ពស់ ដែលមានសាលារៀនជាថ្នាលបណ្តុះបណ្តាល ដឹកនាំ និងគ្រប់គ្រង ដោយនាយកឬនាយិកា និងលោកគ្រូអ្នកគ្រូ ក្រោមការចង្អុលបង្ហាញ គោលដៅពី ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តថែមទៀតផង។

ធនធានមនុស្សដែលល្អជាតម្រូវការចាំបាច់និងសំខាន់បំផុត សម្រាប់រាជរដ្ឋាភិបាល ក្នុងការបម្រើសេវាសាធារណៈ មានគុណប្រយោជន៍ខ្ពស់ដល់ ប្រទេសជាតិ ហើយទាមទារ ឱ្យមានការផ្លាស់ប្តូរ របៀបរបបធ្វើការងារពីអ្នកគ្រប់គ្រង ទៅជាអ្នកផ្តល់សេវា។ សម្រេច បានទិសដៅនេះ តម្រូវឱ្យមានការបណ្តុះបណ្តាលបង្កើនសមត្ថភាព ចំណេះដឹង ចំណេះធ្វើ ព្រមទាំងស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយអ្នកទទួលយកសេវា។ ការអប់រំត្រូវបានទទួល ស្គាល់ថាជាលក្ខខណ្ឌដំបូងសម្រាប់បំពេញឱ្យមនុស្សនូវការងារត្រឹមត្រូវ សមភាពយេនឌ័រ សន្តិភាពនិរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ ទូទាំង ពិភពលោក ព្រោះវាជាមធ្យោបាយដ៏មានសក្តានុពល ក្នុងការកាត់បន្ថយនូវវិសមភាព សម្ភារៈ និងវិសមភាពសេដ្ឋកិច្ច ដែលនាំទៅរកភាពក្រីក្រ។ គុណតម្លៃនេះហើយ បានធ្វើឱ្យ ការអប់រំត្រូវបានក្លាយជាបេះដូង នៃភ្នាក់ងារអភិវឌ្ឍពិភពលោក (Unicef)។

ក្នុងគ្រាបច្ចុប្បន្ននេះ ការអប់រំកុមារតូចនៅប្រទេសកម្ពុជាយើង មើលជាទូទៅឃើញ ថា បាននិងកំពុងពង្រីកវិសាលភាពពេញផ្ទៃប្រទេស ដែលអនុវត្តការផ្តល់សេវាតាម៤រូប ភាពគឺ សេវាមត្តេយ្យសិក្សារដ្ឋ សេវាមត្តេយ្យសិក្សាសហគមន៍ សេវាមត្តេយ្យសិក្សាឯក ជន និងសេវាការអប់រំកុមារតូចតាមផ្ទះឬមាតាបិតា។ ការផ្តល់សេវាចម្រុះបែបនេះ ដើម្បីឆ្លើយតប ទៅនឹងការបំពេញតម្រូវការ បំណិ ននិងការអភិវឌ្ឍរបស់កុមារ។ ដោយសារអនុវិស័យអប់រំ កុមារតូច នៅក្មេងខ្ចីលើការគ្រប់គ្រងផ្អែកលទ្ធផលធានាបាន នូវប្រសិទ្ធភាពក្នុងការប្រើ ប្រាស់ធាតុចូល គុណភាពសេវា និងលទ្ធផលឆ្លើយតបនឹងតម្រូវការរីកចម្រើ ន បែបវិជ្ជមាន របស់កុមារ។ ទើបការកសាងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល ជា មធ្យោបាយដ៏ល្អបំផុត សម្រាប់ជួយដល់ការផ្លាស់ប្តូរ នូវរបៀបបំពេញការងារតាមបែបទម្លាប់ ទៅជាការបំពេញការងារ តាមបែបវិទ្យាសាស្ត្រជឿនលឿន ស្របតាមគោល នយោបាយ កំណែទម្រង់របស់រាជរដ្ឋាភិបាល។ ជាពិសេស គោលនយោបាយកំណែទម្រង់របស់ ក្រសួង អប់រំ យុវជន និងកីឡា។ម្យ៉ាងវិញទៀត គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ក៏ជាអ្នករួមចំណែក ក្នុងការបំពេញនូវសារប្រយោជន៍ សម្រាប់កុមារទាំងអស់ នៅក្នុង ព្រះរាជាណាចក្រកម្ពុជាផងដែរ ព្រោះគណៈកម្មាធិការជាតិ មានក្រសួងស្ថាប័នជាច្រើន ដែលពាក់ព័ន្ធ។

អនុវិស័យអប់រំកុមារតូច មានបញ្ហាប្រឈមធំៗបី ៖ ១.កង្វះធនធានថវិកាដើម្បីធានានូវ ការសម្រេចគោលដៅ នៃសូចនាករផលសម្រេច ២.សមត្ថភាពអង្គភាពមិនទាន់មាំទាំល្អ សម្រាប់ប្រតិបត្តិនូវយន្តការការងារឱ្យបានពេញលេញលើសេវាទាំង៤របស់ខ្លួន ដើម្បីឆ្លើយ តបនឹងគោលនយោបាយអាទិភាពទាំងពីរ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៣.ការសម្រប សម្រួលឆ្លងវិស័យ ដើម្បីបម្រើផលប្រយោជន៍របស់កុមារតូច មានភាពគ្រប់ជ្រុងជ្រោយ ដូចជា: ការអប់រំផ្តល់ពុទ្ធិ ការថែទាំ ការគាំពារ និងការអភិវឌ្ឍសុខភាពនិងអាហារូបត្ថម្ភ។

ឧបសគ្គផ្នែកថវិកា ដែលកំណត់តាមអនុវិស័យមានភាពចង្អៀត និងមិនអាចបំពេញ បានតាមតម្រូវការ របស់អនុវិស័យ ជាហេតុនាំឱ្យការអប់រំកុមារ មិនសម្រេចបានចំណុច ដៅក្នុងផែនការ។ឧបសគ្គផ្នែកសមត្ថភាពរបស់អង្គភាព គឺដោយសារតែសេវាចាំបាច់មួយ ចំនួននៃអនុវិស័យអប់រំកុមារតូចទើបតែចាប់ផ្តើម។ ដូច្នេះការរៀបចំកម្មវិធី យន្តការអនុវត្ត ការងារ ប្រព័ន្ធការងារមិនទាន់បានត្រឹមត្រូវនិងមានភាពសុក្រឹត ទាមទារឱ្យអនុវិស័យ ប្រើពេលវេលាបន្តទៀត ដែលត្រូវខិតខំធ្វើកិច្ចការចាំបាច់ជាច្រើនឱ្យបានច្បាស់ និងរៀន សូត្រ ពីការងារទាំងនោះជាប្រចាំផង។ ចំពោះការសម្របសម្រួលជាមួយ អង្គភាពគាំទ្រ

នានា និងអនុវិស័យផ្សេងទៀត ទាមទារឱ្យអង្គភាពនិងអនុវិស័យនីមួយៗ ទាំងនោះចូលរួម ដែលមានអ្នកដឹកនាំពិតប្រាកដ ដើម្បីធ្វើផែនការអភិវឌ្ឍន៍ របស់អនុវិស័យច្បាស់អាចយក មកអនុវត្តបាន តាមគ្រប់អ្វីដែលបានចែងក្នុងផែនការនិងការពិនិត្យតាមដាន លើការរីក ចម្រើនទាំងលទ្ធផលនិងផលសម្រេច*(ឯកសារប្រព័ន្ធពិនិត្យតាមដាន នៃអនុវិស័យអប់រំកុមារ តូច ២០១៨)*។

ការអប់រំកុមារតូច នៅឆ្នាំសិក្សា២០១៨-២០១៩ សម្រាប់កុមារអាយុ៣ឆ្នាំទទួលបាន ១៨,៥% ដែលចំណុចដៅបានកំណត់៣៥% កុមារអាយុ៤ឆ្នាំទទួលបាន៣៩,៤% ដែល ចំណុចដៅបានកំណត់៤១% សម្រាប់កុមារអាយុ៥ឆ្នាំទទួលបាន៦៣,១% ដែលចំណុចដៅ បានកំណត់រហូតដល់៧០% ( *ឯកសារសន្និបាតអប់រំថ្ងៃទី២៥-២៧ ឆ្នាំ២០១៩ ទំ.៣២)* ។ ដូចច្នេះរដ្ឋត្រូវវិនិយោគថវិកាច្រើនទៀត ដើម្បីសាងសង់សាលា បន្ទប់រៀន ផ្តល់ សម្ភារៈសិក្សា និងជាពិសេសការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយពិនិត្យឃើញថា ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាទូទាំងប្រទេស មាន នៅតែសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមមួយគត់ សម្រាប់បម្រើដល់សេវា អនុវិស័យអប់រំកុមារតូច ដែលជាសេវាសាធារណៈរបស់រដ្ឋ ហើយគរុសិស្សទាំងអស់ ត្រូវបានប្រឡងជ្រើសរើសយកមកពីគ្រប់បណ្តាខេត្តទាំង២៤ រួមជាមួយរាជធានីភ្នំពេញ ផងដែរ ដើម្បីធ្វើការបណ្តុះបណ្តាលរួមគ្នានៅទីនោះ ក្នុងរយៈពេល២ឆ្នាំ ។ការសិក្សា ប្រធានបទនេះ គឺផ្តោតលើបញ្ហាដែលលើកឡើងថា “ការបណ្តុះបណ្តាល គ្រូមត្តេយ្យ សិក្សារដ្ឋ មិនឆ្លើយតប ជាមួយនឹងតម្រូវការរាជធានី ខេត្តនីមួយៗ ឡើយ” តើការពិត នៃបញ្ហានេះបណ្តាលមកពីកត្តាអ្វីខ្លះ? ម្យ៉ាងទៀតគរុសិស្សដែលមកពីបណ្តាខេត្តនានា មានការលំបាកក្នុងការស្នាក់នៅ ដើម្បីសិក្សារៀនសូត្ររបស់ខ្លួន។ តើមានបញ្ហាអ្វីខ្លះ ដែលបណ្តាលឱ្យមានការលំបាកចំពោះពួកគាត់ក្នុងការរស់នៅក្នុងអំឡុងពេលសិក្សា?

ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ឱ្យបានច្រើនគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការ ប្រកបដោយប្រសិទ្ធភាព មិនមែនជារឿងដែលងាយស្រួល និងសមញ្ញពេកនោះឡើយ។ វា ទាមទារនូវអង្គភាពមួយ ដែលមានភាពសព្វគ្រប់ទាំងអស់ ដូចជា: ប្រព័ន្ធគ្រប់គ្រង ការងារ គ្រូឧទ្ទេសមានគុណវុឌ្ឍិពេញលេញ ស្របតាមជំនាញឬមុខវិជ្ជានីមួយៗ ដែលមាននៅក្នុង កម្មវិធីបណ្តុះបណ្តាលរបស់សាលា ការប្តេជ្ញាចិត្តខ្ពស់ទាំងអស់គ្នា ការខិតខំប្រឹងប្រែង

ការចូលរួមពីអ្នកពាក់ព័ន្ធនានា និងការគាំទ្រពីថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាផងដែរ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការស្វែងយល់ពីស្ថានភាព នៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមនេះ គឺដើម្បីស្វែងយល់ពី នាយកសាលា លើការដឹកនាំនិងគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ ការស្នាក់នៅ ការងារបង្រៀននិងរៀនរបស់គ្រូឧទ្ទេសនិងគរុសិស្សឆ្នាំទី១ ក្នុងឆ្នាំសិក្សា២០១៨ –២០១៩។ ម្យ៉ាងទៀតពិនិត្យរកមើលបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធនិងកត្តានីមួយៗខាងដើម រួមជាមួយនឹងការផ្តល់អនុសាសន៍ សម្រាប់ដោះស្រាយ ដោយប្រើវិធីឬរូបមន្តគន្លឹះដែលអ្នកស្រាវជ្រាវស្នើឡើងតាមរយៈការសិក្សា ដើម្បីជំរុញឱ្យសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា បន្តឆ្ពោះទៅអនាគតមានភាពប្រសើរឡើង ប្រកបដោយប្រសិទ្ធភាពនិងឆ្លើយតបទៅនឹងការរីកចម្រើន របស់ប្រទេសជាតិ ព្រោះថាប្រទេសកម្ពុជាកំពុងតែត្រូវការធនធានគ្រូមត្តេយ្យសិក្សាយ៉ាងច្រើន សម្រាប់បម្រើដល់ការអប់រំកុមារតូចៗឱ្យទាន់ពេលវេលាស្របតាម ការអភិវឌ្ឍលូតលាស់លើផ្នែក ទាំង៥របស់ពួកគេនៅគ្រប់ទិសទីទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសធ្វើយ៉ាងណា ឱ្យមានគ្រូមត្តេយ្យសិក្សារដ្ឋ នៅតាមតំបន់ជនបទ និងតំបន់ជួបការលំបាក។

## ១.៤. សំណួរនៃការស្រាវជ្រាវ

១.តើស្ថានភាពនៃការគ្រប់គ្រង របស់នាយកសាលាមធ្យមសិក្សាមត្តេយ្យមជ្ឈិម មានលក្ខណៈដូចម្តេច?

២.តើការបណ្តុះបណ្តាល គ្រូមត្តេយ្យសិក្សានៅទីនោះ ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ជាឯកសារផលិតឡើងក្នុងក្រខណ្ឌវិទ្យាសាស្ត្រ ដែលចាប់តាំងពីចំណុចផ្តើមរហូតដល់ចំណុចបញ្ចប់ គឺមានលក្ខណៈ របៀបរបប បែបបទក្បួនខ្នាតទាំងអស់។ ជាស្នាដៃមួយដែលមានសារៈសំខាន់ណាស់ សម្រាប់ជាវិភាគទានចំពោះវិស័យអប់រំរបស់កម្ពុជាយើង។ ស្នាដៃស្រាវជ្រាវនេះ មានសារប្រយោជន៍ ចំពោះស្មេរជាអ្នកស្រាវជ្រាវផ្ទាល់ ដែលបញ្ជាក់ពីផលនៃការសិក្សាចំពោះ សាលាគរុកោសល្យផ្សេងៗទៀតនិយាយជារួម និងនិយាយដោយឡែកគឺផ្តោតចំពោះ សាលាមធ្យមសិក្សា

គរុកោសល្យមត្តេយ្យមជ្ឈិមខ្លួនឯងផ្ទាល់តែម្តង ដែលបានដឹងពីស្ថានភាពរបស់ខ្លួន ថាមានបញ្ហាអ្វីខ្លះនិងត្រូវធ្វើអ្វីដើម្បីឱ្យសាលារបស់ខ្លួន មាននវានុវត្តន៍ឥតឈប់ឈរល្អប្រសើរ ឆ្ពោះទៅមុខជានិច្ចនិរន្ត ចំពោះនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀត ចំពោះអ្នកកសាងគោលនយោបាយ របស់ក្រសួងអប់រំ យុវជន និងកីឡា ចំពោះអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត និងចំពោះអ្នកអានទូទៅផងដែរ។

### ១.៦. វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺអ្នកសិក្សាស្រាវជ្រាវបានកំណត់យកក្នុងកម្រិតចង្អៀតមួយប៉ុណ្ណោះ ដែលជាការសិក្សាស្រាវជ្រាវប្រភេទករណីសិក្សា ផ្តោតលើតែសាលាគរុកោសល្យតែមួយគត់ គឺសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម នៅក្នុងរាជធានីភ្នំពេញ។ យើងអាចនិយាយបានថា វិសាលភាពនៃករណីសិក្សាស្រាវជ្រាវនេះមានលក្ខណៈពិសេសដោយឡែកជាងគេ ព្រោះថាការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានៅព្រះរាជាណាចក្រកម្ពុជា មានតែមួយកន្លែងនេះប៉ុណ្ណោះ ។ ដូច្នេះធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវកំណត់យកតែម្តងទៅ ដោយគ្មានជម្រើសផ្សេងទៀតឡើយ។ ម្យ៉ាងវិញទៀត ក៏អាស្រ័យលើធនធាននិងពេលវេលា សម្រាប់អ្នកស្រាវជ្រាវ ដែលអាចនឹងអនុវត្តការងារស្រាវជ្រាវរបស់ខ្លួន ប្រព្រឹត្តទៅបានផងដែរ។

### ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖

**ជំពូកទី១**

**១.សេចក្តីផ្តើម៖** បង្ហាញពីលំនាំ ចំណោទបញ្ហា គោលបំណង សំណួរ សារៈសំខាន់ វិសាលភាព រចនាសម្ព័ន្ធ និងកម្មវិធី នៃការស្រាវជ្រាវ។

**ជំពូកទី២**

**២.រំលឹកទ្រឹស្តី៖** បង្ហាញពីពាក្យគន្លឹះ និយមន័យ នៃស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា កញ្ចប់ថវិការដំណើរការសាលារៀន ការដឹកនាំនិងគ្រប់គ្រងរបស់នាយកគ្រូឧទ្ទេស កម្មវិធីបណ្តុះបណ្តាល គុណភាពសម្ភារៈរូបវន្ត ការធ្វើកម្មសិក្សា និងការធ្វើសហការពីសាលារៀន។

**ជំពូកទី៣**

**៣.វិធីសាស្ត្រស្រាវជ្រាវ៖** បង្ហាញពី ប្រភពឯកសារ ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។

## ជំពូកទី៤

**៤.លទ្ធផលស្រាវជ្រាវ៖** បង្ហាញពី លទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលរួមមាន: ព័ត៌មានទូទៅ ការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន ហិរញ្ញវត្ថុ ការស្នាក់របស់គរុសិស្ស និងរបកគំហើញ។

## ជំពូកទី៥

**៥.សេចក្តីសន្និដ្ឋាននិងអនុសាសន៍៖** បង្ហាញពី ការ សន្និដ្ឋានដោយផ្អែកលើលទ្ធផលវិភាគលើចំណុចទាំងឡាយ តាមព័ត៌មានដែលប្រមូលបាន និងការផ្តល់ជា អនុសាសន៍សម្រាប់សាមីសាលានិងអ្នកពាក់ព័ន្ធ។

### ១.៨. កម្មវិធីនៃការស្រាវជ្រាវ

| ល.រ | បរិយាយ | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
|---|---|---|---|---|---|---|---|
| ១ | គម្រោងស្រាវជ្រាវ | ✓ | | | | | |
| ២ | បង្កើតឧបករណ៍ | ✓ | | | | | |
| ៣ | ប្រមូលទិន្នន័យ | ✓ | ✓ | | | | |
| ៤ | សេចក្តីផ្តើម | | | ✓ | | | |
| ៥ | រំឭកទ្រឹស្តី | | | ✓ | | | |
| ៦ | វិធីសាស្រ្ត | | | | ✓ | | |
| ៧ | លទ្ធផល | | | | ✓ | ✓ | |
| ៨ | ការពារសាកល្បង | | | | | ✓ | |
| ៩ | ការពារនិក្ខេបបទបញ្ចប់ | | | | | ✓ | |
| ១០ | ការប្រគល់និក្ខេបបទ | | | | | | ✓ |

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២

## ២.រំលឹកទ្រឹស្តី

### ២.១. ពាក្យគន្លឹះ

- **ស្ថានភាព** គឺជាដំណើរការប្រព្រឹត្តទៅ នៃអ្វីៗក្នុងបរិយាកាសមួយ នៅទីកន្លែងមួយ ដែលមានសភាពបែបបទ ទៅតាមបរិការនោះ។
- **ការគ្រប់គ្រង** គឺជាការទទួលខុសត្រូវដ៏លំបាកមួយ វាទាមទារនូវសមត្ថភាព ចំណេះដឹងច្រើន និងជំនាញខ្ពស់ រួមផ្សំនឹងភាពវៃឆ្លាត រហ័សរហួន ប្រកបដោយភាពប៉ិនប្រសប់ ខាងការរៀបចំចាត់ចែង ដោយគិតគូរសព្វគ្រប់ទាំងផ្នែកចិត្តសាស្ត្រ វប្បធម៌ សាសនា និងនយោបាយផងដែរ។
- **ការដឹកនាំ** គឺជាការធ្វើឱ្យមនុស្សមានការស្ម័គ្រចិត្ត ដើរតាមដោយសុទ្ធចិត្ត ជាមួយអ្នកដឹកនាំឆ្ពោះទៅរកទិសដៅមួយ ដែលបានកំណត់ច្បាស់លាស់ និងមូលហេតុរបស់វា ព្រោះតែមានការជឿទុកចិត្តចំពោះអ្នកដឹកនាំថា នឹងនាំឱ្យមានការផ្លាស់ប្តូររីកចម្រើនពិតប្រាកដ។
- **គុណវុឌ្ឍិ** គឺជាកញ្ចប់ចំណេះដឹងនិងសមត្ថភាពផ្សេងៗ របស់គ្រូឧទ្ទេសស្ថិតនៅតាមកម្រិតនីមួយៗ ដែលខ្លួនគេបានទទួលការបណ្តុះបណ្តាល ពីគ្រឹះស្ថាននានា ដែលមានវិញ្ញាបនបត្រឬសញ្ញាបត្របញ្ជាក់ច្បាស់លាស់។
- **នវានុវត្តន៍** សំដៅលើការល្អលាស់ ប្រែប្រួលរីកចម្រើនជាលំដាប់ មិននៅដដែលជាដដែលនោះទេ វាមានការផ្លាស់ប្តូរថ្មីប្រសើរឡើង គ្រប់ដំណាក់កាលនីមួយៗ។

### ២.២. និយន័យ

#### ២.២.១ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា

ដំណើរការអនុវត្ត ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ដែលមានកម្មវិធីសិក្សាជាក់លាក់ច្បាស់លាស់របស់ជាតិ រយៈពេលសិក្សាត្រូវបានកំណត់ត្រឹមត្រូវ មានគ្រូឧទ្ទេសតាមនិយាមតម្រូវការ មានថវិកាបម្រើឱ្យការបណ្តុះបណ្តាល មានហេដ្ឋារចនាសម្ព័ន្ធសម្ភារៈរូបវន្ត មានទីតាំងសមស្របសម្រាប់ការបង្រៀននិងរៀន របស់គ្រូនិងគរុសិស្ស។

#### ២.២.២កញ្ចប់ថវិកាដំណើរការសាលា

គឺជាថវិកាដែលរដ្ឋបានវិភាជឱ្យដល់សាលារៀនតាមផែនការបានដាក់ស្នើឡើង ដើម្បីដំណើរការការងាររបស់សាលារៀន សម្រាប់ឆ្នាំសិក្សានីមួយៗ។ ម្យ៉ាងទៀតក៏អាច

ជាថវិកាដែលរកបានតាមរយៈមធ្យោបាយផ្សេងៗទៀត របស់គណៈកម្មការសាលារៀន ដូចជាៈ ការធ្វើបុណ្យផ្កាសាមគ្គី ការទទួលបានពីសប្បុរសជននានាជាដើម។

### ២.២.៣ ការដឹកនាំនិងគ្រប់គ្រងរបស់នាយក

ដើម្បីគ្រប់គ្រងការងារបណ្តុះបណ្តាលគ្រូបង្រៀន ទាមទារមានកម្មវិធីនិងគោលដៅច្បាស់លាស់ ដែលធានាបាននូវគុណភាពសមស្រប ជានាយកសាលាមានសមត្ថភាពដល់កម្រិតស្តង់ដា ប្រហាក់ប្រហែលនឹងនាយកសាលាគរុកោសល្យនានា នៅក្នុងតំបន់។ នាយកសាលា ដែលមានលក្ខណៈស្តង់ដា ត្រូវបានបែងចែកជាប្រាំមួយសមាសភាគគឺៈ (១)ភាពជាអ្នកដឹកនាំៈ គណៈគ្រប់គ្រងសាលាគរុកោសល្យ ទាមទារឱ្យ មានទំនាក់ទំនងល្អជាមួយនឹងសហគមន៍ អ្នកពាក់ព័ន្ធនានាដទៃទៀត ដើម្បីអភិវឌ្ឍន៍ឱ្យឆ្លើយតបនឹងចក្ខុវិស័យរបស់ខ្លួន។ ប្រកាន់ខ្ជាប់អនុវត្តការបង្រៀនរបស់គ្រូឧទ្ទេស និងការរៀនរបស់គរុសិស្ស តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ដែលជាគោលការណ៍គ្រឹះ សម្រាប់ការបណ្តុះបណ្តាលនៃសាលាគរុកោសល្យ។ អ្នកដឹកនាំត្រូវរៀបចំណែនាំចាត់ចែងដល់គ្រូឧទ្ទេស ឱ្យបង្រៀនពីមួយឆ្នាំទៅមួយឆ្នាំ គុណភាពប្រសើរឡើង និងបណ្តុះបាននូវស្មារតីសិក្សា ពេញមួយជីវិត។ (២)ការងាររដ្ឋបាលៈ គណៈគ្រប់គ្រងសាលាគរុកោសល្យ ត្រូវលើកទឹកចិត្តចំពោះគរុសិស្សទាំងអស់ដែលខិតខំសិក្សារៀនសូត្រ ប្រកបដោយជោគជ័យ ហើយការងារគ្រប់គ្រង ត្រូវតែធានាបាន នូវការចាត់ចែងការងារសមស្រប មានកិច្ច សហការគ្នារក្សាសណ្តាប់ធ្នាប់បរិយាកាសសិក្សាល្អរបស់គរុសិស្ស និងមានទំនាក់ទំនងល្អរវាងគ្រូឧទ្ទេសផងគ្នា ព្រមទាំងគ្រូឧទ្ទេសនឹងគរុសិស្សផងដែរ ដែលជាការបង្កើតបាននូវ បរិស្ថានសិក្សាល្អ ក្នុងមណ្ឌលនៃសាលាគរុកោសល្យទាំងមូល (៣)ការសិក្សារៀនសូត្រៈ គណៈគ្រប់គ្រងគ្រូឧទ្ទេស និងបុគ្គលិកអប់រំទាំងអស់ ត្រូវ មានការស្រាវជ្រាវវិធីសាស្ត្រថ្មីៗ ដើម្បីឱ្យការអនុវត្តការបង្រៀន និង រៀនប្រកបដោយគុណភាពនិងប្រសិទ្ធភាព ( ៤)អភិវឌ្ឍវិជ្ជាជីវៈ បុគ្គលិកអប់រំៈនាយកសាលាគរុកោសល្យ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ជាមួយក្រុមបច្ចេកទេសគ្រូឧទ្ទេស និងបុគ្គលិកទាំងអស់ ដើម្បីកសាងផែនការប្រតិបត្តិឆ្នាំនិងអនុវត្តផែនការនោះ ដោយមានវិជ្ជាជីវៈធ្វើឱ្យមានការរីកចម្រើន លើគ្រប់ចំណុចទាំងឡាយ ដែលបានកំណត់រួចប្រកបដោយនវានុវត្តន៍ នៃអង្គភាព (៥)សម្ភារៈរូបវន្តៈ គណៈគ្រប់គ្រង សាលាគរុកោសល្យ ត្រូវមានទំនាក់ទំនងជាមួយសហគមន៍ជាតិអន្តរជាតិ ដើម្បីកសាងបន្ថែមនូវអ្វីដែលខ្វះចន្លោះ និងមាន ការគ្រប់គ្រងប្រើប្រាស់សម្ភារៈរូបវន្តទាំងនោះឱ្យមានសក្តានុពល។ គ្រឹះស្ថានបណ្តុះ

បណ្តាលគ្រូជាបទដ្ឋានគម្រូ ដែលជះឥទ្ធិពលលើឥរិយាបថរបស់គរុសិស្ស ក្នុងការផលិត និងការប្រើប្រាស់សម្ភារៈបង្រៀននិងរៀន (៦)សីលធម៌វិជ្ជាជីវៈ នាយកសាលាគរុកោសល្យ ត្រូវប្រកាន់យកក្រមសីលធម៌ក្នុងភាពជាអ្នកដឹកនាំ និងព្រហ្មវិហារធម៌បួន ជាទីទុកចិត្ត ដល់បុគ្គលិកស្ថិតក្រោម ការគ្រប់គ្រងរបស់ខ្លួន ទាំងអស់ ដែលកំពុងបំពេញភារកិច្ចជាផលប្រយោជន៍ដើម្បីសាលាគរុកោសល្យនិងសង្គមជាតិ។ ម្យ៉ាងទៀតចរិយារបស់អ្នកគ្រប់គ្រង វាមានឥទ្ធិពលលើបុគ្គលិកសហគមន៍ និងអ្នកឯទៀត។ដើម្បីគ្រប់គ្រងដឹកនាំ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យ ឈានទៅដល់គោលដៅមួយ ពោលគឺការផលិត ធនធានមនុស្ស ប្រកបដោយគុណភាពនោះ គឺការងារចម្បងសម្រាប់ខ្លួនឯងត្រូវស្រឡាញ់ចូលចិត្ត ការងារ មានសីលធម៌ស្អាតស្អំ មានចិត្តទូលាយ មានបទពិសោធន៍ លើ ការងារអប់រំ យ៉ាងតិច១០ឆ្នាំ មានការសិក្សារៀនសូត្រយ៉ាងហោចទទួលបាន បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ចេះប្រើប្រាស់ភាសាអន្តរជាតិយ៉ាងតិចមួយ (ក្នុងចំណោមភាសាពីរគឺ បារាំងឬអង់គ្លេស) ក្រៅពីភាសាជាតិនិង ទទួលតំណែងតួនាទី ស្របតាមឧបនិស្ស័យ ។ *(នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការៈ២០០៤)*។ ភាពជាអ្នកដឹកនាំគឺជាសមត្ថភាព ដែលអាចនាំ ឬជំរុញអ្នកឯទៀតក្នុងក្រុម អង្គភាព សហការគ្នាទៅតាមតួនាទីនិងភារកិច្ចរៀងៗខ្លួន ធ្វើការដើម្បីសម្រេចគោលដៅ។ រីឯអ្នកដឹកនាំគឺជាបុគ្គល ដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងក្រុម ក្នុងអង្គភាពផ្សេងៗ ដើម្បីឱ្យគេធ្វើជាអ្នកដឹកនាំក្រុម ដឹកនាំអនុវត្តការងារ ដើម្បីសម្រេចគោលបំណង ដែលគេបានគ្រោងទុក។ ក្នុងឯកសារនេះបានបញ្ជាក់ច្បាស់ថា នាយកសាលាមានតួនាទីជាអជ្ញាធរអប់រំ ជាមន្ត្រីរដ្ឋបាល ជាទីប្រឹក្សាគរុកោសល្យ ជាអធិការអប់រំអចិន្ត្រៃយ៍ និងជាភ្នាក់ងារអភិវឌ្ឍសហគមន៍ ហើយគាត់មានភារកិច្ចទទួលខុសត្រូវ លើ ការងាររដ្ឋបាល ការងារបច្ចេកទេសគរុកោសល្យ និងការងារទំនាក់ទំនង *(គោលនយោបាយស្តីពី គ្រូបង្រៀនៈ២០១៣)*។

ការពង្រឹងប្រសិទ្ធភាពអ្នកដឹកនាំ សាលារៀនជារឿងដែលមិនអាចខ្វះបាន គឺត្រូវពង្រឹងយន្តការភាពជាអ្នកដឹកនាំឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនេះសកម្មភាពដែលពិសេសក្នុងគោលនយោបាយស្តីពីគ្រូបង្រៀន គឺ ត្រូវបណ្តុះបណ្តាលនាយក គ្រឹះស្ថានសាធារណៈ លើខ្លឹមសារចំណេះដឹងជំនាញ ការសិក្សាស្រាវ ជ្រាវភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការងារគ្រប់គ្រង ភាពជាអ្នកដឹកនាំ ការពិនិត្យតាមដាន និងវង្វាយតម្លៃ។ ការ បណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់ លើខ្លឹមសារសមត្ថភាពវិជ្ជាជីវៈ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងថ្នាក់រៀន គរុកោសល្យ វិធី

សាស្ត្របង្រៀន បច្ចេកទេសដែលទាក់ទងទៅនឹងការងារគ្រូបង្រៀន និងចំណេះដឹងទាក់ទងទៅនឹងគោលនយោបាយស្តីពីគ្រូបង្រៀននិងផលប្រយោជន៍ ដែលទទួលបានពីការអនុវត្តគោលនយោបាយជាដើម*(នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ:២០១១)*។

### ២.២.៤គ្រូឧទ្ទេស

គ្រូឧទ្ទេសត្រូវបង្រៀនសិស្សឱ្យមានសត្តភាព និងបំណិនពេញលេញប្រកបដោយវិជ្ជាសម្បទា បណិនសម្បទាំ និងចរិយសម្បទា តាមរយៈការអនុវត្ត គោលវិធីសិស្សមជ្ឈមណ្ឌល ការលើកទឹកចិត្ត ការកសាងសមត្ថភាព លើជំនាញដោះស្រាយបញ្ហា ការធ្វើកិច្ចការតាម បែបសហការ មិនមានការ រើសអើង និងមានវិធីសាស្ត្របង្រៀនផ្សេងៗ ក្នុងការបង្រៀន ដើម្បីផ្លាស់ប្តូរបរិយាកាសថ្នាក់រៀន ក៏ដូចជាការដឹកនាំការបង្រៀន និងរៀន មានភាពសកម្ម *(R. Chepkemoi Willitter, et al : 2013)*។

ចំពោះគ្រូបង្រៀនក្នុងភារកិច្ចជាសិក្ខាបនធារី ជាកម្លាំងអប់រំចម្បងជួយសិស្សានុសិស្សដោយផ្ទាល់ ឱ្យសម្រេចភារកិច្ចរៀនសូត្ររបស់ពួកគេ ដែលនេះគឺជាភារកិច្ចស្នូលរបស់សាលារៀន ហើយគ្រូបង្រៀនត្រូវតែបង្រៀនមុខវិជ្ជានីមួយៗ តាមវិធីសាស្ត្រដែលក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ឱ្យ ក៏ដូចជាវិធីសាស្ត្រថ្មីៗទៀត ដែលខ្លួនបានរកឃើញឬយល់ថាមានអត្ថប្រយោជន៍។ មិនតែប៉ុណ្ណោះ ដើម្បីអភិវឌ្ឍសម្បទា ចិត្ត គរុកោសល្យរបស់ខ្លួន ហើយដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ ទាមទារឱ្យគ្រូបង្រៀនមានការស្រាវជ្រាវ ឯកសារទាក់ទងទៅនឹង វិធីសាស្ត្របង្រៀនឱ្យបានច្រើន និងត្រូវទទួលខុសត្រូវ ក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបដោយគុណភាព *(នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការ:២០០៤)* ។

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺជាសេចក្តីអធិប្បាយសង្ខេបនិងច្បាស់លាស់ នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀន ត្រូវយល់ដឹងនិងធ្វើ។ វាជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀន ដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស។ វាជាឧបករណ៍សម្រាប់វាស់សមត្ថភាព ដែលស្តែងចេញរបស់គ្រូបង្រៀន។ ក្នុងឯកសារនេះក៏បានបញ្ជាក់ផងដែរថា ដើម្បី ឱ្យការបណ្តុះបណ្តាលគ្រូបង្រៀន មានកម្មវិធីនិងទិសដៅច្បាស់លាស់ ធានាបាននូវគុណភាពសមស្រប ក្នុងការលើកស្ទួយការបង្រៀននិងរៀនរបស់គ្រូបង្រៀន ក៏ដូចជា ជួយសម្រួលការសិក្សារបស់សិស្ស ឱ្យទទួលបានលទ្ធផលល្អសមស្របនិងអាចទទួលយកបាន គ្រូបង្រៀន ត្រូវមានសមត្ថភាព ដល់ស្តង់ដាមួយសមស្រប ឬក៏ ប្រហាក់ប្រហែលនឹងគ្រូបង្រៀនក្នុងតំបន់។ ក្រសួងអប់រំ យុវជន និងកីឡា

បានបង្កើតឡើងនូវស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន សម្រាប់ការអនុវត្តទូទាំង ប្រទេស។ ដូច្នេះ ដើម្បីបញ្ជាក់ថាគ្រូបង្រៀនម្នាក់ៗ មានសមត្ថភាពដល់ស្តង់ដានេះ ទីមួយពួកគាត់ត្រូវមាន ចំណេះដឹងវិជ្ជាជីវៈត្រឹមត្រូវ។ គ្រូបង្រៀនដែលមាន ចំណេះដឹងវិជ្ជាជីវៈត្រឹមត្រូវសម្បូរបែប គឺពួកគាត់ត្រូវតែដឹងច្បាស់ ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សានិងឥរិយាបថ របស់សិស្សម្នាក់ៗច្បាស់លាស់ ហើយត្រូវយល់ដឹងផងដែរ ពីប្រភេទគ្រួសារ និងកត្តា ផ្សេងៗដែលមានឥទ្ធិពល ដល់ការសិក្សារបស់សិស្ស (យេនឌ័រពិការភាព ក្រុមជនជាតិ ភាគតិច)ជាដើម។ បន្ថែមពីនេះគ្រូបង្រៀនត្រូវ ដឹងពីវិធីដោះស្រាយ ទៅលើកត្តាទាំងនោះ របស់សិស្សផងដែរ។ គ្រូបង្រៀនត្រូវយល់ដឹងបានច្បស់សាល់ ពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ហើយពេញចិត្តក្នុង ការអនុវត្តនៅសាលារៀន។ គ្រូបង្រៀនត្រូវយល់ពីទ្រឹស្តី ក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជាៈ វត្ថុបំណង វិធីសាស្រ្តបង្រៀន និងអាចធ្វើការជ្រើសរើសវិធីវាយតម្លៃ លទ្ធផល សិក្សាសមស្រប។ គ្រូបង្រៀនយល់ពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់ មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយ ផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។ គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀប រៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យល្បឿន និងរបៀបសិក្សាដែលមាន ឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ ទីពីរការប្រតិបត្តិវិជ្ជាជីវៈត្រឹមត្រូវ គ្រូបង្រៀនត្រូវរៀប ចំកិច្ចតែងការបង្រៀន ឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាមកម្មវិធី សិក្សា ដោយផ្អែកលើសៀវភៅសិស្សសៀវភៅគ្រូ និងសម្ភារៈសិក្សាផ្សេងៗទៀត ដែល អាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀន ត្រូវរៀបចំសម្ភារៈបង្រៀន និងរៀន ដើម្បីរិះរកមធ្យោបាយសម្រេច ការសិក្សារបស់សិស្ស ប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ត្រូវប្រើប្រាស់ វិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សផ្សេងៗគ្នា ដែលស្រប ទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្សម្នាក់ៗ។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មាន ត្រឡប់ទៅសិស្សមាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍន៍ចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូប នូវបរិស្ថានសិក្សាប្រកបដោយ សុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាពព្រមទាំង លើកទឹកចិត្តសិស្សឱ្យ កាន់តែមានការទទួលខុសត្រូវ ចំពោះការសិក្សារបស់ខ្លួននិងចូលរួម ក្នុងការអភិវឌ្ឍសាលា រៀន ដើម្បីគាំទ្រការសិក្សានិងសុខមាលភាព របស់សិស្សនិងគ្រូបង្រៀនឯទៀត។ គាត់

ត្រូវចេះប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែប ដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចវត្ថុបំណងមេរៀន។ ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាព ផ្តល់ជាមធ្យោបាយ ឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្ស តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀន ដ៏សម្បូរបែបដោយផ្តល់ ឱកាសឱ្យសិស្សចូលរួមគិត ឱ្យបានល្អិតល្អន់និងដោយច្នៃប្រឌិត។ លើសពីនេះទៀតគ្រូបង្រៀន ត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព។ ទីបីគឺការសិក្សាស្រាវជ្រាវវិជ្ជាជីវៈជាប្រចាំ យើងបានដឹងហើយថា គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្តនិងជាអ្នកធានា ឱ្យសិស្សទទួលបានជោគជ័យ ក្នុងការសិក្សា។ ដូច្នេះពួកគាត់ត្រូវតែស្វ័យសិក្សាវាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការ សម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំ ស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ លើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការអាននិងការស្រាវជ្រាវ ប្រភពឯកសារផ្សេងៗ ដើម្បីពង្រឹងចំណេះដឹងឱ្យបានទូលំទូលាយ ក្នុងន័យកែលំអការបង្រៀន និងរៀន ហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀត ក្នុងការសិក្សាវិជ្ជាជីវៈ។ ទីបួនគឺមានសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ ក្នុងវិជ្ជាជីវៈគ្រូបង្រៀន ដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្ស ដោយប្រកាន់ខ្ជាប់នូវ មនសិការវិជ្ជាជីវៈ និងគោរពឱ្យបានពេញលេញ នូវ ក្រមសីលធម៌គ្រូបង្រៀននិងច្បាប់ស្តីពីការអប់រំ។ គ្រូបង្រៀនត្រូវគោរពពេលវេលា ធ្វើការងារ តាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងថ្នាក់ សាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមគ្រប់សកម្មភាពទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀន ឱ្យបានសមស្របតាមករណី ដែលអាចធ្វើបាន។ គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាបញ្ហាយេនឌ័រ ជនជាតិ ភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថៃទាំសិស្ស ផ្តល់លទ្ធភាព ឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ ក្នុងការពិនិត្យលទ្ធផលសិក្សារបស់សិស្ស។ នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្ស ដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហិង្សាឡើយ។ គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ សម្រាប់ការសហការជាមួយសហការី និងមាតាបិតាសិស្ស ដើម្បីផលប្រយោជន៍សិស្ស ផ្តល់ជាគំរូដល់សិស្សក្នុងការរស់នៅ

និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹងនិងវិជ្ជមាន ហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះសហគមន៍ទាំងមូល *(នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ២០១០)*។ មាត្រា៧បានចែងថា "គ្រូបង្រៀន ស្តាប់ពិនិត្យ ឱ្យដំបូន្មាន ឬធ្វើអាណាព្យាបាល អ្នកសិក្សាទូទៅដោយមិនលម្អៀង និងមិនប្រកាន់អំពីប្រភពអាយុ ភេទ ពូជសាសន៍ ដើមកំណើត ពណ៌សម្បុរ ពិការភាព យេនឌ័រ ជំនឿសាសនា និន្នាការនយោបាយឬឋានៈសង្គម ធនធានឬស្ថានភាពឯទៀតនៅក្នុងការអប់រំ និងសេវាអប់រំ។ នៅក្នុងនោះមាត្រា៨បានចែងផងដែរថា"គ្រូបង្រៀនត្រូវប្រកាន់ខ្ជាប់ នូវមនសិការវិជ្ជាជីវៈ។ គ្រូបង្រៀនមានករណីកិច្ច រៀបចំកិច្ចតែងការបង្រៀននិងកំណត់ការពន្យល់ សំដៅធានាគុណភាពនិងប្រសិទ្ធភាពនៃការបង្រៀន។ ចំណែកមាត្រា៩បានចែងថា "គ្រូបង្រៀនត្រូវស្វ័យសិក្សានិងស្រាវជ្រាវ សម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ។ គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈបង្រៀន"*(គោលនយោបាយស្តីពី គ្រូបង្រៀនៈ២០១៣)*។ ដើម្បីកសាងនិងអភិវឌ្ឍគ្រូបង្រៀន ឱ្យមានចំណេះដឹងជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ប្រកបដោយគុណភាព សមត្ថភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ ក្នុង ការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ដោយមានការទទួលស្គាល់ពីសង្គម គឺត្រូវធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន ធានាការអនុវត្តវិជ្ជាជីវៈគ្រូបង្រៀន ក្នុងពេលបម្រើការងារជាប្រចាំ និងធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀន ក្នុងការបំពេញការងារ ប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តសិទ្ធិ។ ដូច្នេះដើម្បីសម្រេចឱ្យបាន នូវការបង្កើនគុណភាពគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់ស្តង់ដា ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន មិនតែប៉ុណ្ណោះត្រូវអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យប្រែក្លាយសាលាគរុកោសល្យ ទៅជាមជ្ឈមណ្ឌលអប់រំគ្រូបង្រៀន បង្កើនគុណវឌ្ឍិនិងបទពិសោធបុគ្គលិកអប់រំ នៅមជ្ឈមណ្ឌលអប់រំគ្រូបង្រៀន ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអប់រំគ្រូបង្រៀន ដើម្បីអនុវត្តវិជ្ជាជីវៈគ្រូបង្រៀន។ មិនតែប៉ុណ្ណោះការពង្រឹងប្រសិទ្ធភាព ការប្រើប្រាស់គ្រូបង្រៀនតាមនិយាម និងការ ប្រើប្រាស់គ្រូបង្រៀនតាមគោលការណ៍។ អនុវត្តសមត្ថភាពគ្រូបង្រៀន ក្នុ ងពេលបម្រើការងារដោយបណ្តុះវប្បធម៌រៀនពេញមួយជីវិត ដោយចេះចែករំលែកចំណេះដឹង និងបទពិសោធជាក្រុមក្នុងចំណោមបណ្តាញអ្នកអប់រំ *(ច្បាប់ស្តីពីការអប់រំៈ២០០៧)*។ មាត្រា២០ ការបណ្តុះបណ្តាល

បុគ្គលិកអប់រំបានចែងថា "រដ្ឋត្រូវបណ្តុះបណ្តាលបុគ្គលិកអប់រំមុនពេល និងក្នុងពេលកំពុងបម្រើការងារ។ បុគ្គលិកអប់រំត្រូវឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យ ដែលទទួលស្គាល់ដោយក្រសួង ទទួលបន្ទុកវិស័យអប់រំ លើកលែងតែសាស្ត្រាចារ្យ និងបុគ្គលិកដែលបម្រើការក្នុងស្ថាប័នថ្នាក់ឧត្តមសិក្សា។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់កម្មវិធីគោល សម្រាប់ការបណ្តុះបណ្តាលបុគ្គលិកអប់រំ កំណត់កាយសម្បទា និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈ សម្រាប់ការជ្រើសរើសបុគ្គលិកអប់រំសាធារណៈនិងឯកជន"។ ស្តង់ដាគឺជាលក្ខណៈ លំនាំគំរូឬជាខ្នាតគំរូ ដែលគេសន្មត់យកមកប្រើប្រាស់ សម្រាប់វាស់គុណភាពនៃវត្ថុឬផលិតផលអ្វីមួយ។ ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គឺជាការកំណត់ឬកម្រិតលក្ខណៈគំរូ ដោយសន្មត់មួយសម្រាប់ការអភិវឌ្ឍការងារបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានភាពប្រសើរឡើងទាំងផ្នែកគាំទ្រនិងអនុវត្ត ហើយមានលក្ខណៈអាចវាស់វែងបានតាមរយៈការពិព័ណ៌នាស្តង់ដា សំដៅឱ្យអ្នកអនុវត្តបានយល់និងឱ្យបានសម្រេច នូវសូចនាករទាំងនោះ។ ស្តង់ដានេះជាឧបករណ៍បង្ហាញផ្លូវ សម្រាប់កែលម្អគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ គ្រប់ផ្នែកទាំងរូបវន្ត សកម្មភាព និងគុណភាព។ ចំណែកឯ គ្រូឧទ្ទេសត្រូវមានបទពិសោធបង្រៀន នៅសាលាចំណេះទូទៅយ៉ាងតិច៣ឆ្នាំ មានសមត្ថភាពជ្រៅជ្រះក្នុងវិជ្ជាជីវៈ មានសីលធម៌ និងប្រវត្តិការងារល្អ គោរពវិន័យ និងមានភាពទៀងទាត់ក្នុងការងារចេះ ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ចេះភាសាអង់គ្លេស ភាសាបារាំង មានកម្រិតជំនាញទាបបំផុតបរិញ្ញាបត្រអប់រំ។ ចំណែកឯបុគ្គលិកផ្សេងៗទៀត ក៏ត្រូវមានសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា មានសីលធម៌ឧស្សាហ៍ព្យាយាមស្រឡាញ់ការងារ និងមានវិន័យការងារទៀងទាត់ *(នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការស្តីពីការបណ្តុះបណ្តាលគ្រូបង្រៀន)*។ រដ្ឋ ត្រូវធានាការផ្តល់គ្រូបង្រៀនគ្រប់កម្រិតសិក្សា ប្រកបដោយប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងការពង្រីកប្រព័ន្ធអប់រំ រួមទាំងការពង្រីកសមត្ថភាពអ្នកគ្រប់គ្រងសាលាគរុកោសល្យ និងអ្នកគ្រប់គ្រងអប់រំគ្រូឧទ្ទេស នាយកសាលារៀន និងមន្ត្រីអប់រំសំខាន់ៗផ្សេងទៀត។ ក្នុងវត្ថុបំណងទី៣គឺកែលម្អគុណភាពនៃការបង្រៀនតាមរយៈការពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន។ ក្នុងនោះដែរដើម្បីឆ្លើយតបទៅនឹង គោលនយោបាយនិងយុទ្ធសាស្ត្រវិស័យអបរំ គឺត្រូវលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ តាមរយៈការលើកកម្ពស់ ការអភិវឌ្ឍគ្រូបង្រៀនទាំងការបណ្តុះបណ្តាលនិងវិក្រឹតការ។ ត្រូវបង្កើនសមត្ថភាពបុគ្គលិក នៅសាលាគរុកោសល្យទាំងអស់ រួមមានការបំប៉នគ្រូឧទ្ទេស តាមរយៈកម្មវិធីអភិវឌ្ឍបុគ្គលិកនៅសាលាគរុកោសល្យ។ ត្រូវបំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់

កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងការអប់រំបញ្ចូលគ្នា ជូនដល់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សា។ ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ ដល់គ្រូឧទ្ទេស និងគ្រូមធ្យមសិក្សាទាំងអស់។ ត្រូវបំប៉នសមត្ថភាពស្តីពី ការបញ្ជ្រាបយេនឌ័រជូនដល់ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ការពង្រឹងសមត្ថភាពគ្រប់គ្រង របស់អ្នកដឹកនាំនៅគ្រប់សាលាគរុកោសល្យគឺ ត្រូវពង្រឹងសមត្ថភាពគ្រូឧទ្ទេស អំពីវិធីសាស្រ្តបង្រៀន ដូចជាការសិក្សាស្រាវជ្រាវមេរៀន និងការសិក្សាតាមបែបរិះរក( Lesson Study and Inquiry Base Learning)។ ត្រូវបំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការអភិវឌ្ឍ និងប្រើប្រាស់សម្ភារឧបទេស។ ត្រូវបំប៉នគ្រូឧទ្ទេសសាលាគរុកោសល្យស្តីពី ការប្រើប្រាស់ឧបករណ៍ពិសោធន៍ជាដើម។ ការពង្រឹងសមត្ថភាពមន្ត្រី នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ គឺជារឿងមិនអាចខ្វះបានដើម្បីកំណត់សកម្មភាពជាអាទិភាពសំដៅ ធ្វើឱ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព តាមរយៈការរៀបចំផែនការសកម្មភាព សម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន អភិវឌ្ឍផែនការសកម្មភាព សម្រាប់ពង្រឹងនិងពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន។ វាយតម្លៃកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន រួមមាន ផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលគ្រូ សម្រាប់តំបន់ជនបទតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក*(គម្រោងលើកកម្ពស់គុណភាពអប់រំEEQPអគ្គនាយកដ្ឋានអប់រំ)*។ ដើម្បីពង្រឹងគុណភាពអប់រំនៅតាមសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តោតការគាំទ្រយ៉ាងហ្មត់ចត់បំផុតចំពោះការអភិវឌ្ឍ និងការគ្រប់គ្រងអប់រំ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងការពង្រឹងការអប់រំនៅមធ្យមសិក្សា។ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ជាចាំបាច់គឺត្រូវតែលើកកម្ពស់សមត្ថភាពគ្រប់គ្រង ស្ថាប័នបណ្តុះបណ្តាលគ្រូ ត្រូវធ្វើឱ្យប្រសើរឡើងនូវសម្ភាររូបវ័ន្តរួមទាំងICT នៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូ ត្រូវ បង្កើនការចូលរៀនរបស់គរុសិស្សនារី និងគរុសិស្សមកពីតំបន់ជួប ការលំបាកនៅសាលាគរុកោសល្យរាជធានី-ខេត្ត និងវិទ្យាស្ថានជាតិអប់រំ ។ត្រូវ បង្កើនសមត្ថភាពនិងបំណិនគ្រូឧទ្ទេសនៅ ក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ ត្រូវបង្កើនសមត្ថភាព និងបំណិនគ្រូបង្រៀននៅមធ្យមសិក្សា ត្រូវណែនាំឱ្យចេះពីរបៀបប្រើប្រាស់ប្រព័ន្ធ ផ្សព្វផ្សាយចម្រុះ សម្រាប់ការងារបណ្តុះបណ្តាលគ្រូជាចម្បងសិន(N. Harris and R. Sass:2008)។ បានបង្ហាញថា មានសណ្ឋានតែពីរគត់នៃការបណ្តុះបណ្តាលគ្រូ ដែលមានអានុភាពលើផលិតភាព នៃការបង្រៀន។ ទីមួយគឺការផ្តោតទៅលើខ្លឹមសារ នៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀន គឺជាចំណែកដ៏វិជ្ជមានបំផុតទៅលើផលិតភាព ក្នុងការបង្រៀនគណិតវិទ្យានិងទីពីរគ្រូបង្រៀន ដែល

មានបទពិសោធន៍ច្រើន បានលេចឡើងនូវ ប្រសិទ្ធភាពយ៉ាងខ្លាំងក្នុងការបង្រៀនអំណាន និងគណិតវិទ្យា នៅថ្នាក់បឋមសិក្សា ហើយក៏គ្មានភស្តុតាងណាបានបញ្ជាក់ថា សម្បទាទាំងការសិក្សា និងការបណ្តុះបណ្តាលរបស់និស្សិត ដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀន មានឥទ្ធិពលទៅលើសមត្ថភាពរបស់ពួកគេ ក្នុងការបង្កើននូវលទ្ធផលសិក្សា របស់សិស្សនោះដែរ*(Department for Education:2010)*។ ភស្តុតាងជាច្រើនមកពី ប្រព័ន្ធអប់រំខុសៗគ្នាជុំវិញពិភពលោក បានបង្ហាញថា កត្តាដែលសំខាន់បំផុតក្នុងការកំណត់ ថាតើ សិស្សធ្វើបានល្អកម្រិតណានោះ គឺអាស្រ័យទៅលើ គុណភាពគ្រូ និងការបង្រៀន។ ដោយសារហេតុផលនេះហើយទើបពួកគេត្រូវស្រូប ឬអូសទាញគ្រូបង្រៀនរបស់ពួកគេ ពីក្នុងចំណោមអ្នកដែលបញ្ចប់ការសិក្សាកំពូលៗ ហើយបង្វឹកពួកគេយ៉ាងហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព ដោយផ្តោតសំខាន់ទៅលើការអនុវត្ត នៅក្នុងថ្នាក់រៀន ដើម្បីទទួលបានប្រព័ន្ធអប់រំដ៏ល្អបំផុត នៅក្នុងពិភពលោក។ បន្ទាប់មកពួកគេត្រូវធ្វើឱ្យ ប្រាកដថាគ្រូបង្រៀនទាំងនោះ បានទទួលនូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈប្រកប ដោយប្រសិទ្ធភាពតាមរយៈអាជីពរបស់ពួកគេជាមួយនឹងឱកាសក្នុងការសង្កេត និងធ្វើការជាមួយគ្រូបង្រៀនផ្សេងទៀតហើយនឹងទទួលបាន នូវការបណ្តុះបណ្តាលសមរម្យ សម្រាប់តួនាទីជាអ្នកដឹកនាំ *(UNESCO ២០១៣-២០១៤)*។ ប្រទេសដែលមានលទ្ធផលសិក្សាខ្ពស់ តម្រូវឱ្យគរុសិស្សទទួលបានការបណ្តុះបណ្តាលអំពី ការអនុវត្តថ្នាក់រៀនមុនពេលចេញបង្រៀនដូចជា: ឱ្យពួកគេចេះរៀបចំកិច្ចតែងការបង្រៀននិងរៀបចំកិច្ចសរសេរសមស្របតាមកម្រិតថ្នាក់ សម្រាប់ថ្នាក់គួបផងដែរ ដែលមានសិស្សមានអាយុផ្សេងគ្នា សមត្ថភាពខុសគ្នាក៏ដូចជារបៀបប្រើប្រាស់គោលវិធី សិស្សមជ្ឈមណ្ឌល។ ជាពិសេសជាងនេះទៀតនោះ សមត្ថភាពរបស់គ្រូ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ជាធនធានមិនអាចខ្វះបាន ក្នុងការបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការលើកកម្ពស់ការរៀនសូត្រ។ គេបានរកឃើញទៀតថា ការប្រើប្រាស់Internetរបស់គ្រូ ជាធនធានគរុកោសល្យដែលបានគាំទ្រ ដល់ការបង្រៀននិងរៀនក្នុងថ្នាក់រៀនបែបច្នៃប្រឌិតថ្មី ដែលជាលទ្ធផលនាំឱ្យមានការកែលម្អពិន្ទុតេស្តរបស់សិស្ស ដើម្បីធានាយ៉ាងណាឱ្យគ្រូ អាចទទួលបានការបណ្តុះបណ្តាលល្អបំផុត ក្នុងការលើកកម្ពស់ការរៀនសូត្រ របស់សិស្សទាំងអស់គ្នាវាជាការសំខាន់ណាស់ដែលការបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានចំណេះដឹង និងបទពិសោធជាមួយនឹងបញ្ហាប្រឈម ក្នុងការបង្រៀននៅក្នុងថ្នាក់ពិតប្រាកដ និងរបៀបដោះស្រាយបញ្ហាទាំងនោះ។ ដូច្នេះអ្នកតាក់តែងគោលនយោបាយគួរធានាយ៉ាងណា ឱ្យគ្រូឧទ្ទេសទទួលបានការបណ្តុះ

បណ្តាល និងមានបទពិសោធគ្រប់គ្រាន់ ជាមួយនឹងតម្រូវការនៃការរៀនសូត្រ នៅក្នុងកាលៈទេសៈដែលមានការលំបាកនិងរៀបចំឱ្យមានអ្នកជួយណែនាំ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ។ វត្ថុបំណង នៃកម្មវិធីបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជា គឺធ្វើឱ្យប្រាកដថាបានផ្គត់ផ្គង់គ្រូ ប្រកបដោយប្រសិទ្ធភាពសម្រាប់ការអប់រំនៅគ្រប់កម្រិត។ ដូច្នេះដើម្បីឱ្យឆ្លើយតបទៅនឹង តម្រូវការនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពនៃការគ្រប់គ្រងដឹកនាំ នៅសាលា បណ្តុះបណ្តាលគ្រូ គណៈគ្រប់គ្រងសាលា អ្នករដ្ឋបាល គ្រូឧទ្ទេស និងបុគ្គលិកដទៃៗទៀត ហើយត្រូវឱ្យប្រាកដថា គរុសិស្សដែលបានចូលមកបណ្តុះបណ្តាល នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យ មជ្ឈិម មានចំនួនឆ្លើយតបទៅនឹងតម្រូវការទូទាំងប្រទេស មានគុណវុឌ្ឍិពេញលេញ ឆ្លើយតបទៅនឹងសម័យកាលបច្ចុប្បន្ន។ ជាពិសេសជាងនេះទៀត គឺការធ្វើឱ្យប្រសើរឡើង នូវគុណភាពនៃការបង្រៀននិងរៀន តាមរយៈការជំរុញឱ្យស្រាវជ្រាវ និងប្រើប្រាស់វិធីបង្រៀនថ្មីៗនៅក្នុងតំបន់និងសាកលលោក *(គោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥)*។

### ២.២.៥កម្មវិធីបណ្តុះបណ្តាល

ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន កម្មវិធីបណ្តុះបណ្តាលជាផែនទីបង្ហាញផ្លូវ ដែលនាំទៅដល់គោលដៅ។ បើផែនទីបង្ហាញផ្លូវនេះមិនសូវល្អ នោះការសម្រេចគោលដៅក៏ទទួលបានមិនសូវល្អដែរ ផ្ទុយមកវិញបើផែនទីបង្ហាញផ្លូវល្អប្រសើរនោះ ការសម្រេចគោលដៅនឹងទទួលបានប្រកបដោយគុណភាព។ មុនចូលបម្រើការងារនិងអំឡុងពេលបម្រើការងារ នឹងជួយឱ្យគ្រូបង្រៀន មានសមត្ថភាពគ្រប់គ្រងសៀវភៅសិក្សាគោល បានល្អនៅក្នុងសាលារៀន សៀវភៅសិក្សាគោលបានជួយយ៉ាងច្រើនដល់គ្រូបង្រៀនគ្រប់រូប។ ដូច្នេះដើម្បីផ្លាស់ប្តូរ ឱ្យការបង្រៀនប្រកបដោយគុណភាព ត្រូវការកែលម្អឡើងវិញនូវកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន និងបុគ្គលិកនៅក្នុងស្ថាប័នបណ្តុះបណ្តាល និងវិក្រិតការនាពេលបច្ចុប្បន្ន ហើយការផ្លាស់ប្តូរដ៏ធំធេង និងគួរឱ្យកត់សម្គាល់មួយនេះ ត្រូវមានការអន្តរាគមន៍មួយចូលខ្លួនមកនោះគឺសាលារៀនត្រូវមានសៀវភៅសិក្សាគោល ដែលលើកកម្ពស់វិធីសាស្ត្របង្រៀន និងវិធីរៀនថ្មីៗ។ ប្រសិនបើអាច មានសៀវភៅសិក្សាបែបនេះយ៉ាងសំបូរបែប និងទូលំទូលាយនោះ សៀវភៅទាំងនេះ នឹងអាចជួយសម្រួលដល់គ្រូបង្រៀន តាមរយៈការផ្តល់ឧទាហរណ៍ស្តីពីវិធីសាស្ត្របង្រៀនថ្មី ព្រមទាំងអនុញ្ញាតឱ្យសិស្សានុសិស្ស អាចធ្វើអន្តរកម្មជាមួយព័ត៌មានបាន បើទោះបីជាគុណភាព នៃការបង្រៀននៅមានកម្រិតក៏ដោយ។ ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការអប់រំឱ្យ

ស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងសង្គម ពុទ្ធិផ្អែកលើចំណេះដឹង ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកសាងផែនការជាបន្តបន្ទាប់ជាពិសេសនោះ គឺការកសាងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននេះ តែម្តងដែលកម្មវិធីនោះតែងតែត្រូវ បានធ្វើការកែលម្អជាបន្តបន្ទាប់ សម្រាប់ឱ្យគ្រូបង្រៀនយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព និងដើម្បីឱ្យឆ្លើយតបទៅនឹង គោលនយោបាយសំខាន់ៗ និងផែនការបណ្តុះបណ្តាល ដូចជា រដ្ឋធម្មនុញ្ញ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលដៅអប់រំជាតិ គោលបំណងនៃកម្មវិធីបណ្តុះបណ្តាល រចនាសម្ព័ន្ធនៃកម្មវិធីបណ្តុះបណ្តាល ផែនការបណ្តុះបណ្តាល របាយម៉ោងតាមមុខវិជ្ជានីមួយៗ ចំណេះដឹងមូលដ្ឋាន ចំណេះដឹងបឋមសិក្សា និងវិធីសាស្រ្តបង្រៀនតាមមុខវិជ្ជានីមួយៗ ជាដើម។ មិនតែប៉ុណ្ណោះកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន បានកសាងគ្រូបង្រៀនឱ្យក្លាយជា ឪពុកម្តាយទីពីរ ជាគ្រូពេទ្យ និងជាទីប្រឹក្សារបស់សហគមន៍ផងដែរ។ ជាមួយនោះផងដែរ តាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សារយៈពេលពីរឆ្នាំ បន្ទាប់ពីពួកគេបញ្ចប់ការសិក្សាគរុសិស្សនឹងក្លាយជាគ្រូបង្រៀន ដែលមានចំណេះដឹងទូទៅមុខវិជ្ជានានា និងជំនាញវិជ្ជាជីវៈច្បាស់លាស់ មានបំណិនក្នុងការបង្រៀន និងអប់រំទាំងការងាររដ្ឋបាល គ្រប់គ្រងប្រកបដោយការច្នៃប្រឌិត និងមានទម្លាប់ស្វ័យសិក្សាស្រាវជ្រាវជាប្រចាំ មានសីលធម៌គុណធម៌ និងចេះរួមរស់ជាមួយអ្នកដទៃ មានស្មារតីចូលរួមអភិវឌ្ឍមូលដ្ឋាន និងប្រទេសជាតិ តាមរយៈការចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ ជាពិសេសអប់រំណែនាំមាតាបិតាសិស្សឱ្យបញ្ជូនកូនចៅចូលសាលារៀន ។



កម្មវិធីបណ្តុះបណ្តាល មានការកំណត់ចំនួនម៉ោងនិងភាគរយ លើការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈចំណេះដឹងមូលដ្ឋាន ការ បណ្តុះបណ្តាលចំណេះដឹងមត្តេយ្យសិក្សា និងវិធីសាស្រ្តបង្រៀន ការស្រាវជ្រាវគរុកោសល្យ និងកម្មសិក្សាគរុកោសល្យច្បាស់លាស់ សម្រាប់រយៈពេល២ឆ្នាំ នៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សា គរុកោសល្យមត្តេយ្យមជ្ឈិម។

### ២.២.៥.១ ផែនការបណ្តុះបណ្តាល

| ល.រ | ខ្លឹមសារ | ឆ្នាំទី១ | ឆ្នាំទី២ | សរុប |
|---|---|---|---|---|
| ១ | ត្រៀមរៀបចំពិធីបើកវគ្គ | ១សប្តាហ៍ | ១សប្តាហ៍ | ២សប្តាហ៍ |
| ២ | អនុវត្តកម្មវិធីសិក្សាតាមមុខវិជ្ជា | ៣០សប្តាហ៍ | ២៨សប្តាហ៍ | ៥៨សប្តាហ៍ |
| ៣ | កម្មសិក្សាគរុកោសល្យ | ៦សប្តាហ៍ | ៨សប្តាហ៍ | ១៤សប្តាហ៍ |
| ៤ | ឈប់សម្រាកវិស្សមកាលតូច | ៦សប្តាហ៍ | ៦សប្តាហ៍ | ១២សប្តាហ៍ |
| ៥ | រៀនសាឡើងវិញត្រៀមប្រឡង | ១សប្តាហ៍ | ១សប្តាហ៍ | ២សប្តាហ៍ |
| សរុប | | ៤៤សប្តាហ៍ | ៤៤សប្តាហ៍ | ៨៨សប្តាហ៍ |

**កំ.សំ** គ្រូឧទ្ទេសប្រជុំបច្ចេកទេសរាល់ថ្ងៃព្រហស្បត្តិ៍ រយៈពេល៣ម៉ រីឯគរុសិស្សធ្វើពលកម្មសម្អាតទីធ្លាសាលា។

ផែនការនៃការបណ្តុះបណ្តាល បានកំណត់ខ្លឹមសារ សម្រាប់ឆ្នាំទី១ និងទី២ ដែលគិតជាចំនួនសប្តាហ៍ គឺឆ្នាំសិក្សាទី១និងទី២ មានចំនួន៤៤សប្តាហ៍ដូចគ្នា។ ដូច្នេះសរុបចំនួនសប្តាហ៍ទាំងពីរឆ្នាំសិក្សា គឺ៨៨សប្តាហ៍ សម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា។

### ២.២.៥.២ មុខវិជ្ជាដែលត្រូវបណ្តុះបណ្តាលរួមមានៈ

| ល.រ | មុខវិជ្ជា | ឆ្នាំទី១ | ឆ្នាំទី២ |
|---|---|---|---|
| ១ | ចិត្ត–គរុកោសល្យ | ✓ | ✓ |
| ២ | ភាសាខ្មែរ | ✓ | ✓ |
| ៣ | គណិតវិទ្យា | ✓ | ✓ |
| ៤ | សរីរវិទ្យា | ✓ | ✓ |
| ៥ | អប់រំកាយនិងចិត្តចលភាព | ✓ | ✓ |
| ៦ | សីលធម៌ ពលរដ្ឋវិជ្ជា | ✓ | ✓ |

| | | | |
|---|---|---|---|
| ៧ | គេហវិជ្ជា | ✓ | ✓ |
| ៨ | ភាសាអង់គ្លេស | ✓ | ✓ |
| ៩ | កសិកម្ម រោងជាង | ✓(កសិកម្ម) | ✓(កសិកម្ម) |
| ១០ | បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ | ✓ | ✓ |
| ១១ | វិទ្យាសាស្ត្រងាយៗនៅមត្តេយ្យសិក្សា | ✓ | ✓ |
| ១២ | អប់រំសិល្បៈ | ✓ | ✓ |
| ១៣ | កម្មសិក្សាគរុកោសល្យ | ✓ | ✓ |
| ១៤ | ការស្រាវជ្រាវគរុកោសល្យ | ✓ | ✓ |
| ១៥ | សកម្មភាពកសាង | ✓ | ✓ |
| ១៦ | វប្បធម៌ទូទៅ | ✓ | ✓ |
| ១៧ | សីលធម៌វិជ្ជាជីវៈ | ✓ | X |
| ១៨ | សិទ្ធិកុមារ សិទ្ធិមនុស្ស និងសិទ្ធិស្ត្រី | ✓ | ✓ |
| ១៩ | យេនឌ័រ | ✓ | X |
| ២០ | កម្មវិធីកុមារមេត្រី | ✓ | ✓ |
| ២១ | ការអប់រំបញ្ចូលគ្នា | X | ✓ |
| ២២ | ថ្នាក់គួប | X | ✓ |
| ២៣ | រដ្ឋបាលសិក្សា | ✓ | ✓ |
| ២៤ | បណ្ណាល័យ | ✓ | ✓ |
| ២៥ | បរិស្ថាន | X | ✓ |

មុខវិជ្ជាសំខាន់ៗនិងខ្លឹមសារមេរៀនបញ្ជ្រាប សម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា រយៈពេល២ឆ្នាំមានទាំងអស់ រហូតដល់២៥មុខវិជ្ជាសំខាន់ៗ រួមនឹងខ្លឹមសារមេរៀនបញ្ជ្រាប*(កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យ"១២+២"នា.បណ្តុះបណ្តាលនិងវិក្រឹតការឆ្នាំ២០១៣)*។

### ២.២.៦គុណភាពសម្ភារៈរូបវន្ត

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមាន ធនធានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ដូចជាត្រូវមានសៀវភៅនិងឯកសារស្រាវជ្រាវគ្រប់គ្រាន់មានសម្ភារៈព័ត៌មានវិទ្យា សម្រាប់បង្រៀនគរុសិស្សគ្រប់គ្រាន់មានសម្ភារៈឧបទ្ទេស សម្រាប់ការបង្រៀននិងរៀនគ្រប់គ្រាន់

មានសម្ភារៈពិសោធន៍គ្រប់មុខវិជ្ជាគ្រប់គ្រាន់ មានតុកៅអីសម្រាប់គរុសិស្សអង្គុយសិក្សា មានសម្ភារៈការពារសុវត្ថិភាពត្រឹមត្រូវ មានសម្ភារៈកីឡានិងសិល្បៈគ្រប់គ្រាន់ មានសម្ភារៈរោងជាងកាត់ដេរនិងគេហវិជ្ជាគ្រប់គ្រាន់ មានសម្ភារៈកសិកម្មសម្រាប់ការងារដាំដំណាំ។ មិនតែប៉ុណ្ណោះ នៅ ក្នុងអន្តេវាសិកដ្ឋានក៏ត្រូវមានសម្ភារៈ ប្រើប្រាស់គ្រប់គ្រាន់ដែរដូចជាសម្ភារៈផ្ទះបាយសម្ភារៈប្រើប្រាស់ ក្នុងបន្ទប់ស្នាក់នៅនិងសម្ភារៈអនាម័យជាដើម*(ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនក្រសួងអយក.)*។

**២.២.៧ការធ្វើកម្មសិក្សានិងកិច្ចសហការពីសាលា**

ការកសាងភាពរឹងមាំតាមរយៈ ការចុះកម្មសិក្សាគរុកោសល្យរបស់គរុសិស្ស នៅទូទាំងអឺរ៉ុប សហរដ្ឋអាមេរិក និងអូស្ត្រាលីគឺជាគម្រូមួយដែលត្រូវលើកទឹកចិត្ត ឱ្យប្រើប្រាស់។ សាកលវិទ្យាល័យនិងសាលាផ្សេងៗទៀត ដែលបានចូលរួមសហការជាមួយមហាវិទ្យាល័យនានាដែលបណ្តុះបណ្តាលគ្រូបង្រៀនគឺជាដៃគូដ៏សំខាន់និងខ្លាំងក្លា ដែលបានបំផុសឡើងតាមរយៈការបណ្តុះបណ្តាលគ្រូ ផ្អែកលើតម្រូវការពីសាលារៀន ដោយមានគោលបំណងរួមតែមួយរវាងសាលានានា នឹង សាលាបណ្តុះបណ្តាលគ្រូ។ ការ អនុវត្តការបណ្តុះបណ្តាលគ្រូ អាស្រ័យលើតម្រូវការគ្រូពីសាលារៀន គឺធ្វើឱ្យគរុសិស្សមានការចូលរួមសិក្សារៀនសូត្រ ទទួលបាននូវចំណេះដឹងជំនាញច្បាស់លាស់ និង អនុវត្តការបង្រៀននៅសាលាដែលចុះធ្វើកម្មសិក្សាដោយយកចិត្តទុកដាក់ ដើម្បីបានក្លាយទៅជាគ្រូមានគុណវុឌ្ឍិដ៏ប្រសើរម្នាក់។ ដូច្នេះដើម្បីឱ្យការអនុវត្តនេះទទួលបានជោគជ័យ គឺទាមទារឱ្យសាលាបណ្តុះបណ្តាលគ្រូ សហការយ៉ាងជិតស្និទ ជាមួយនឹងសាលាដែលគរុសិស្សរបស់ខ្លួនត្រូវចុះធ្វើកម្មសិក្សាជាមួយ ដើម្បី ទទួលស្គាល់នូវភាពខ្លាំង និងចំណុចខ្វះខាតរបស់គរុសិស្ស និងអាចជួយដល់ពួកគេឱ្យបានល្អប្រសើរ និងទាន់ពេលវេលា។ការសហការរវាងសាលានានានិងសាលាបណ្តុះបណ្តាលគ្រូ មិនត្រឹមតែផ្តល់ចំណេះដឹងដល់គរុសិស្សប៉ុណ្ណោះទេប៉ុន្តែថែមទាំងបណ្តុះបាន នូវប្រពៃណីសហ ការ អភិវឌ្ឍនូវជំនាញអាជីព ដែលជាប្រព័ន្ធលើកទឹកចិត្តរបស់អង្គភាព និងរវាងអង្គភាពមួយនឹងអង្គភាពដទៃផ្សេងទៀតដែរ។ សាលារៀនដែលសហការទាំងនោះ គឺជាកន្លែងរៀនដ៏ប្រសើរបំផុត សម្រាប់អភិវឌ្ឍសមត្ថភាពរបស់គរុសិស្ស សូម្បីតែគ្រូឧទ្ទេសអ្នកស្រាវជ្រាវ និងអ្នកគ្រប់គ្រង ក៏ទទួលបានបទពិសោធផងដែរ។ សាលាគរុកោសល្យ ជាកន្លែងបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនដែលទទួលបាននូវតួនាទីថ្មី និងមានការទទួលខុសត្រូវក្នុងការចូលរួមដោះស្រាយបញ្ហា ចូលរួមក្នុង ការសម្រេចចិត្ត ចូលរួមក្នុង ការរៀបចំឧបករណ៍វាយតម្លៃសិស្ស ចូលរួមការអភិវឌ្ឍបុគ្គលិក ចូលរួមក្នុង ការអភិវឌ្ឍចំណេះដឹងនិងជំនាញ។ ទន្ទឹមនឹងនោះសាលា

បណ្តុះបណ្តាលគ្រូ  ក៏ជាកន្លែងអភិវឌ្ឍកម្មវិធីសិក្សាផងដែរ  ព្រោះថាការសហការគ្នារវាងដៃគូ គឺជាបទពិសោធដ៏ប្រសើរសម្រាប់អប់រំកុមារ។ បុគ្គលិកចូលរួមស្វែងរក និងវាយតម្លៃលើការអនុវត្តថ្មី ការរិះរក និងណែនាំនូវដំណើរការរៀន ក៏ដូចជាការអភិវឌ្ឍនៅក្នុងស្ថាប័ន ឬអង្គភាពផងដែរ។ការសហការជាមួយដៃគូទទួលបាននូវសារៈប្រយោជន៍បីយ៉ាងដូចជា: (១)អភិវឌ្ឍគុណភាពគ្រូបង្រៀន (  ២)ការបង្កើតបាននូវភាពប្រាកដនិយម និងបង្កើតនូវបរិយាកាសផ្សេងៗនៃការរៀននិងការបង្រៀន ( ៣)ការបង្កើតបាននូវវប្បធម៌មួយ  នៃសហប្រតិបត្តិការ  និងការរួមដៃគ្នារវាងមហាវិទ្យាល័យអប់រំនិងសាលានានា  ទៅលើទិដ្ឋភាពខុសគ្នា នៃការបង្រៀននិងរៀន(Chirsttopher Bessina, et al. no year)។ គោលបំណងនៃកម្មសិក្សាគរុកោសល្យ  គឺបើកឱកាសឱ្យគរុសិស្ស  បានហ្វឹកហាត់ការងាររបស់ខ្លួនដោយផ្ទាល់ នៅក្នុងថ្នាក់រៀនជាក់ស្តែង ដែល ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង នៅតាមសាលាគោលដៅ សម្រាប់ចុះធ្វើកម្មសិក្សា។  ទន្ទឹមនឹងនេះ កម្មសិក្សាគរុកោសល្យ  បានធ្វើឱ្យគរុសិស្សបានសិក្សាស្វែងយល់ពី ស្ថានភាពជាក់ស្តែងនិងភាពបត់បែន ជាមួយនឹងស្ថានការដែលប្រឈមចំពោះមុខ តាមរយៈការសង្កេត និងផ្ទាល់ជាមួយសិស្ស ដើម្បីទុកជាមេរៀនពិសោធន៍និងជាមូលដ្ឋានគ្រឹះ  នៃចំណេះដឹងវិជ្ជាជីវៈរបស់ខ្លួន។  បណ្តុះបំណិនវិជ្ជាជីវៈគ្រូបង្រៀនដល់គរុសិស្ស ដើម្បីឱ្យគេក្លាយជាគ្រូបង្រៀនល្អ ប្រកបដោយមនសិការ និងស្មារតីទទួលខុសត្រូវខ្ពស់។ ផ្តល់ឱកាសឱ្យសាលាគរុកោសល្យ និងសាលាមត្តេយ្យសិក្សាសហការគ្នាបានល្អ ក្នុងការរួមចំណែកបណ្តុះបណ្តាលគ្រូបង្រៀន ប្រកបដោយគុណភាព។ ការវាយតម្លៃសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនរបស់គរុសិស្ស ក្រោយពីការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ នៅសាលាគរុកោសល្យ ដើម្បីមានវិធានការកែលម្អបានទាន់ពេលវេលា។ ទ្រឹស្តីខាងលើនេះបានបង្ហាញថា មានកត្តាច្រើនយ៉ាងណាស់រួមផ្សំគ្នា ដើម្បីធ្វើឱ្យដំណើរការនៃការបណ្តុះបណ្តាលគ្រូ  ទទួលបាននូវគុណភាពនិងប្រសិទ្ធភាពខ្ពស់។ តែទោះបីជាយ៉ាងណា  ការបណ្តុះបណ្តាលគ្រូ ដែល ទទួលបានគុណភាពនិងប្រសិទ្ធភាពលុះត្រាតែមានលក្ខណៈដូចខាងក្រោម៖

គុណភាពនិងប្រសិទ្ធភាព
នៃការបណ្តុះបណ្តាលគ្រូបង្រៀន

- គុណភាពនាយក
- គុណភាពគ្រូឧទ្ទេស
- គុណភាពកម្មវិធីសិក្សា
- គុណភាពសម្ភារៈរូបវន្ត
- មានកិច្ចសហការល្អ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

## ៣.វិធីសាស្ត្រស្រាវជ្រាវ

### ៣.១. ប្រភពឯកសារ

ដើម្បីសម្រេចគោលបំណង នៃការសិក្សាស្រាវជ្រាវទាមទារឱ្យមាន ការស្វែងរកទិន្នន័យនិងព័ត៌មាន ឯកសារពាក់ព័ន្ធនានាឱ្យបានគ្រប់គ្រាន់ ពីប្រភពផ្សេងៗដូចជា: តាមបណ្ណាល័យនានា តាមអង្គភាពពាក់ព័ន្ធ ជាពិសេសនៅអង្គភាព ដែលត្រូវធ្វើការសិក្សាស្រាវជ្រាវ និងតាមអ៊ីនធ័រណេតជាដើម។ ព័ត៌មានដែលយើងប្រមូលបាន គឺមានពីរប្រភេទ ទី១មានពីប្រភពដែលគេបានចងក្រងជាសំណៅឯកសាររួចហើយ និងទី២ ជាព័ត៌មានបានពីការដាក់ឱ្យអ្នកផ្តល់ព័ត៌មានបំពេញកម្រងសំនួរ និងកម្រងសំណួរសួរដោយផ្ទាល់មាត់ ពីអ្នកស្រាវជ្រាវ។

### ៣.២. ការជ្រើសរើសភាគសំណាក

ភាគសំណាកដែល ត្រូវបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវ សម្រាប់ប្រធានបទខាងលើនេះគឺជ្រើសរើសយកចំគោលដៅតែម្តង ដោយដៅយកតែភាគសំណាកណាដែលអ្នកសិក្សាស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវ ទិន្នន័យបានជាក់លាក់ឬច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះភាគសំណាក ដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យ ដែលអាចទទួលយកបាន រួមមានគណៈគ្រប់គ្រង(នាយក នាយិការង) ចំនួន០៣នាក់ គ្រូឧទ្ទេសចំនួន២១នាក់និងគរុសិស្សជំនាន់ទី៣២ ឆ្នាំទី១នៃឆ្នាំសិក្សា២០១៨-២០១៩ ចំនួន២០០នាក់ប៉ុណ្ណោះ។

### ៣.៣. ឧបករណ៍ស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យ គឺអ្នកស្រាវជ្រាវបានចងក្រងបង្កើតកម្រងសំណួរ ដែលមានលក្ខណៈជា សំណួរបិទនិងសំណួរបើក សម្រាប់ធ្វើសម្ភាសន៍ដល់ក្រុមគោលដៅ រួមមាន៖ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្សជំនាន់ទី៣២ ឆ្នាំទី១ នៃឆ្នាំសិក្សា ២០១៨-២០១៩។ កម្រងសំនួរដែលបានបង្កើតឡើង នៅក្នុងឧបករណ៍ប្រមូលទិន្នន័យ គឺផ្អែកលើឯកសារពាក់ព័ន្ធនានាជាច្រើន ដែលផលិតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសឯកសារស្តង់ដានាយកសាលារៀន *(នា.បណ្តុះបណ្តាលនិងវិក្រឹតការ ឆ្នាំ២០១៧)* និងឯកសារជាច្រើនផ្សេងៗទៀត។

កម្រងសំនួរដែលបានបង្កើតឡើងមានចែកជាប្រាំផ្នែកធំៗគឺ៖

ផ្នែកទី១ ៖ព័ត៌មានទូទៅ ទាក់ទងនឹង ភេទ អាយុ តួនាទី ការបណ្តុះបណ្តាលកម្រិតវិជ្ជាជីវៈ និងកម្រិតបណ្តុះបណ្តាលចុងក្រោយ ភាសាបរទេស កុំព្យូទ័រ រយៈពេលបម្រើការងារ

ផ្នែកទី២ ៖ ការដឹកនាំគ្រប់គ្រង ទាក់ទងនឹងការយល់ដឹងលើគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីកំណែទម្រង់ដែលសាលាត្រូវអនុវត្ត ចក្ខុវិស័យ បេសកកម្មរបស់សាលា គណៈកម្មការទ្រទ្រង់របស់សាលា គ្រូឧទ្ទេស និងមុខវិជ្ជាឯកទេស ការវាយតម្លៃបុគ្គលិក និងបំណងប្រាថ្នាសម្រាប់សាលា។

ផ្នែកទី៣ ៖ ការបង្រៀននិងរៀន ទាក់ទងនឹង សម្ភារៈដំណើរការបង្រៀននិងរៀន កិច្ចតែងការបង្រៀន ក្លិបសិក្សា ការជួយគរុសិស្សរៀនយឺត ការសង្កេតថ្នាក់រៀននិងលទ្ធផលសិក្សារបស់គរុសិស្ស។

ផ្នែកទី៤ ៖ ផ្នែកហិរញ្ញវត្ថុ ទាក់ទងនឹង ថវិកានិងប្រភពថវិកា ការប្រើប្រាស់និងការទូទាត់។

ផ្នែកទី៥ ៖ ការស្នាក់នៅរបស់គរុសិស្ស ទាក់ទងនឹងអន្តេវាសិកដ្ឋាន ការស្នាក់នៅក្នុង និងការស្នាក់នៅក្រៅ។

## ៣.៤. ការប្រមូលទិន្នន័យ

បន្ទាប់ពីបានផលិត ឧបករណ៍ប្រមូលទិន្នន័យរួច ក៏បានឆ្លងការផ្តល់យោបល់ពីសាស្ត្រាចារ្យដឹកនាំ និងទទួលបានការអនុញ្ញាតឱ្យចុះធ្វើការប្រើប្រាស់ ប្រមូលទិន្នន័យនៅសាលាគោលដៅ ដោយមានលិខិតជម្រាបជូនចំពោះសាលាគោលដៅ លេខ១៨៨៥ អយក.វជអ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតឧទ្ទេសនាម លេខ១១៩ វជអ.ផក ចុះថ្ងៃទី១៧ ឧសភា ឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិអប់រំ។ ដើម្បីទទួលបាននូវទិន្នន័យ សម្រាប់ធ្វើការវិភាគប្រធានបទខាងលើអ្នកសិក្សាស្រាវជ្រាវបានចុះទៅជួប ក្រុមមុខសញ្ញាគោលដៅ នៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីធ្វើសម្ភាសន៍ និងពន្យល់ណែនាំឱ្យបំពេញចម្លើយលើសំណួរនីមួយៗ ក្នុងឧបករណ៍ប្រមូលទិន្នន័យ ឱ្យបានជាក់លាក់ជាព័ត៌មានត្រឹមត្រូវពិតប្រាកដ និងជាព័ត៌មានបច្ចុប្បន្នភាព ការបំពេញចម្លើយលើកម្រងសំណួរទាំងអស់ នៃឧបករណ៍ប្រមូលទិន្នន័យមានរយៈ២៥នាទី និងបញ្ចប់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩ ។

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលប្រមូលបានមក គឺ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ កុំព្យូទ័រ ដោយកម្មវិធី MicrosoftExcel និងកម្មវិធី SPSSផងដែរ។ ការវិភាគប្រធានបទស្រាវជ្រាវនេះ គឺប្រើទាំងបែបបរិមាណវិស័យផង និងបែបគុណវិស័យផង ដោយបង្កើតជាក្រាហ្វិកជាក្រាបផ្លិត និងក្រាបសសរ។ សំណួរមួយចំនួនត្រូវបានវិភាគបកស្រាយ តាមបែបបរិមាណវិស័យ និងមួយចំនួនទៀតត្រូវធ្វើការវិភាគតាមបែបពហុវិស័យវិញ។

ឧបករណ៍ប្រមូលទិន្នន័យដែលគ្រោង គឺគណៈគ្រប់គ្រងសាលាចំនួន០៣នាក់ បានបំពេញខ្លឹមសារ និងផ្ដល់ឧបករណ៍ប្រមូលទិន្នន័យមកវិញ បានតែ០២នាក់ គ្រូឧទ្ទេសចំនួន២១នាក់ បានបំពេញខ្លឹមសារ និងផ្ដល់ឧបករណ៍ប្រមូលទិន្នន័យមកវិញ បានតែ១១នាក់ និងគរុសិស្សចំនួន២០០នាក់ បានបំពេញខ្លឹមសារនិងផ្ដល់ឧបករណ៍ប្រមូលទិន្នន័យមកវិញ បានតែ១៨៣នាក់។ សរុបឧបករណ៍ដែលទទួលមកវិញ សម្រាប់គណៈគ្រប់គ្រងសាលា និងគ្រូឧទ្ទេសចំនួន១៣នាក់ និងគរុសិស្សចំនួន ១៨៣នាក់។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤

## ៤. លទ្ធផលស្រាវជ្រាវ

### ៤.១. លទ្ធផល

បន្ទាប់ពីប្រមូលនិងធ្វើការទិន្នន័យដែលប្រមូលបាន តាមសំណាកគម្រូទាំងនោះ ជាលទ្ធផលវិភាគ អំពីស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានដូចខាងក្រោម៖

### ៤.១.១ព័ត៌មានទូទៅ

គណៈគ្រប់គ្រងសាលាចំនួន០៣នាក់ និងគ្រូឧទ្ទេសចំនួន១៥នាក់ សរុប១៨នាក់ ដែលជាចំណុចដៅប្រមូលព័ត៌មាន ជាក់ស្តែងមានគណៈគ្រប់គ្រងពីរនាក់និងគ្រូឧទ្ទេសចំនួន១២នាក់ ដែលបានផ្តល់ព័ត៌មាន ស្មើនឹង៧៧.៧៨% ក្នុងនោះស្រី០៧នាក់ ស្មើនឹង៥០% ។គរុសិស្សចំនួន២០០នាក់ ក្នុងចំណុចដៅសម្រាប់ប្រមូលព័ត៌មានជាក់ស្តែងមានគរុសិស្សចំនួន១៨៣នាក់ បានផ្តល់ព័ត៌មាន ស្មើនឹង៩១.៥០% ស្រី១៧៣នាក់ ស្មើនឹង៨៦.៥%។

- **កម្រិតអាយុគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស**



- **កម្រិតអាយុរបស់គរុសិស្ស**




គរុសិស្សមានកម្រិតអាយុខុសគ្នា រហូតដល់១១ក្រុមអាយុ ដែលរៀននៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ក្នុងជំនាន់នេះ។ ពោលគឺអាយុរបស់គរុសិស្សស្ថិតនៅចន្លោះពី១៧ឆ្នាំដល់៣២ឆ្នាំ សបញ្ជាក់ឱ្យឃើញថា មានគរុសិស្សតិចតួចបំផុត ដែលប្រឡងជាប់ធ្វើជាគ្រូបង្រៀន បន្ទាប់ពីការប្រឡងជាប់សញ្ញាបត្រធម្យមសិក្សាទុតិយភូមិ។ កត្តានេះអាចបណ្តាលមកពី  ការប្រឡងចូលធ្វើជាគ្រូបង្រៀននេះ មានភាពប្រកួតប្រជែងខ្លាំង បានជាអ្នកដែលទើបចេញពីសាលាថ្មីៗ ហើយគ្មានបទពិសោធ មិនអាចប្រឡងជាប់ជាគ្រូបង្រៀន។

- **សញ្ញាបត្រចុងក្រោយសម្រាប់គណ:គ្រប់គ្រងនិងគ្រូឧទ្ទេស**



ជារួមគុណវុឌ្ឍិនៃគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស នៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ដែលឆ្លុះបញ្ចាំងតាមរយៈសញ្ញាបត្រចុងក្រោយរបស់ពួកគាត់ បង្ហាញថា មាន៩៣% ស្ថិតក្រោមកម្រិតបរិញ្ញាបត្រនៅឡើយ តែបរិញ្ញាបត្រជាន់ខ្ពស់ក៏មានរហូតដល់ ៣៦%ដែរ។ មានការស្រាវជ្រាវជាច្រើនបានបង្ហាញឱ្យឃើញថា គុណភាពគ្រូជាកត្តាចម្បងក្នុងការកំណត់ ពីភាពជោគជ័យនៃការសិក្សារបស់សិស្ស។ គុណភាពគ្រូសំដៅជំបូងគេបង្អស់ គឺកម្រិតសញ្ញាបត្រ ដូច្នេះកម្រិតសញ្ញាបត្រដែលទាបជាងកម្រិតបរិញ្ញាបត្រ របស់គ្រូឧទ្ទេសនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមនេះ សបញ្ជាក់ឱ្យឃើញថា កម្រិតគុណវុឌ្ឍិរបស់គ្រូឧទ្ទេសភាគច្រើននៅទាបនៅឡើយ ដែលមិនទាន់សមនឹងស្តង់ដាគ្រូបង្រៀន ជាពិសេសស្តង់ដាគ្រូបង្រៀនបណ្តាប្រទេស ជាសមាជិកសមាគមអាស៊ីអាគ្នេយ៍។

- **ភាសាបរទេសចំពោះគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស**




ចំពោះគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស អ្នកដែលមានយល់ដឹងលើភាសាបរទេសទទួលបានលទ្ធផលភាគច្រើនបំផុតស្ថិតក្នុងកម្រិតមធ្យម។ លទ្ធផលនេះ បង្ហាញឱ្យឃើញថា លទ្ធភាពនៃការអភិវឌ្ឍវិជ្ជាជីវៈ នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម គឺមានកម្រិតត្រឹមតែការបញ្ជូនឱ្យទៅបណ្តុះបណ្តាលនៅក្នុងប្រទេស មិនអាចបញ្ជូនឱ្យទៅបណ្តុះបណ្តាលនៅក្រៅប្រទេសបានទេ។ បើចង់ធ្វើការបណ្តុះបណ្តាលនៅក្រៅប្រទេស លុះត្រាតែប្រើរយៈពេលវែង គឺទី១ត្រូវបណ្តុះបណ្តាលពួកគាត់ នូវចំណេះដឹងទូទៅភាសាអង់គ្លេស និងភាសាជំនាញភាសាបរទេសទៀត ទើបអាចបញ្ជូនទៅសិក្សានៅក្រៅប្រទេសបាន។

- **ភាសាបរទេសចំពោះ គរុសិស្ស**




ចំពោះគរុសិស្ស ការយល់ដឹងភាសាបរទេស ភាគច្រើនបំផុតក៏ទទួលបាននៅក្នុងកម្រិតមធ្យមដែរ ហើយក៏មានលទ្ធផលល្អនិងល្អប្រសើរខ្លះផងដែរ។ លទ្ធផលនេះអាចបកស្រាយបានថា កម្រិតភាសាបរទេសដែលបណ្ដុះបណ្ដាល នៅសាលាមធ្យមសិក្សាគរុកោសស្យមត្តេយ្យមជ្ឈិម នៅមានកម្រិតទាបនៅឡើយ។ កត្តានេះអាចបណ្ដាលមកពីគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូនេះ មិនមានគ្រូឧទ្ទេសលើផ្នែកភាសាបរទេសគ្រប់គ្រាន់ ឬអាចយកគ្រូឧទ្ទេស ដែលមិនមានឯកទេសមកបង្ហាត់បង្រៀន។ ស្ថានភាពនេះទាន់អាចឆ្លើយតបទៅនឹងស្តង់ដាសមត្ថភាពគ្រូបង្រៀន អាស៊ានទេ ដែលតម្រូវឱ្យគ្រូបង្រៀនមានសមត្ថភាពភាសាបរទេសមួយយ៉ាងតិច ក្រៅពីភាសាកំណើតរបស់ខ្លួន។ ដូច្នេះទាមទារឱ្យគ្រឹះស្ថានមួយនេះ ត្រូវមានផែនការច្បាស់លាស់ក្នុងការអភិវឌ្ឍ សមត្ថភាពគ្រូឧទ្ទេសមិនត្រឹមតែលើកម្រិតគុណវុឌ្ឍិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំនាញភាសាបរទេសផងដែរ។ លទ្ធផលសិស្សវាបានឆ្លុះបញ្ចាំង ពីកម្មវិធីសិក្សារបស់សាលា ការអនុវត្តកម្មវិធីសិក្សាសមត្ថភាពរបស់គ្រូ មធ្យោបាយគាំទ្រនានា ការបង្រៀនរបស់គ្រូឧទ្ទេស ចំពោះគរុសិស្ស និងការខិតខំយកចិត្តទុកដាក់រៀនសូត្ររបស់គរុសិស្ស ដែលថ្ងៃខាងមុខដ៏ខ្លីនឹងក្លាយជាគ្រូបង្រៀនយ៉ាងពិតប្រាកដ សម្រាប់ផ្ដល់ចំណេះដឹងដំបូងគេបង្អស់ដល់កុមារ។ ដូច្នេះសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម គួរពង្រឹងឱ្យលើការបង្រៀនភាសាបរទេសនេះឱ្យមានភាពប្រសើរឡើង។

- **ការប្រើប្រាស់កុំព្យូទ័រ ចំពោះគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស**




សមត្ថភាពប្រើប្រាស់កុំព្យូទ័រ សម្រាប់គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស ផ្តោតលើកម្មវិធីចំនួនបីគឺ Word, Excell និងPower Point អ្នកដែលអាចប្រើប្រាស់កម្មវិធីទាំងបី មាន៨% និងអ្នកអាចប្រើប្រាស់ត្រឹមកម្មវិធីWord មាន៦៩ %។ លទ្ធផលនេះបង្ហាញថា គណៈគ្រប់គ្រង និងគ្រូឧទ្ទេសរបស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម នៅមានសមត្ថភាពទាបនៅឡើយ ក្នុងការប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាន សម្រាប់យកមកប្រើប្រាស់បម្រើឱ្យវិធីសាស្រ្តបង្រៀនបែបថ្មី នាយុគសម័យឌីជីថល៤.០ ដែលទាមទារឱ្យការវិនិយោគដ៏ធំលើផ្នែកនេះ បើក្រសួងចង់ពង្រឹងគុណភាព នៃការបណ្តុះបណ្តាលដំបូងនិងបន្តបន្ទាប់ដល់គ្រូមត្តេយ្យសិក្សា ពោលគឺត្រូវវិនិយោគលើការបណ្តុះបណ្តាលគ្រូឧទ្ទេសជាមុន។

- **ការប្រើប្រាស់កុំព្យូទ័រ ចំពោះគរុសិស្ស**



គរុសិស្សភាគច្រើនបំផុត អាចបើកកុំព្យូទ័របានត្រឹមកម្មវិធី Word និងអាចប្រើកម្មវិធី Excel គ្រាន់បើជាងPowerpointដែលអាចប្រើWordបានមានរហូតដល់៦៨.៣០% ចំណែក Powerpoint ទាបជាងគេ មានត្រឹមតែ៩.៣០%ប៉ុណ្ណោះ។ លទ្ធផលនេះសញ្ជាក់ឱ្យឃើញថា សមត្ថភាពនៃការប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាន របស់គរុសិស្សជំនាន់ទី៣២ ឆ្នាំទី១ នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម នៅមានកម្រិតដែលទាមទារឱ្យមានការកែពិនិត្យមើលកម្មវិធីបណ្តុះបណ្តាលឡើងវិញ ឬពង្រឹងការបង្ហាត់បង្រៀនលើផ្នែកនេះ ឱ្យមានប្រសិទ្ធភាព ដើម្បីឱ្យការបណ្តុះបណ្តាលគ្រូឆ្លើយតបទៅនឹងបរិបទថ្មី នៃកម្មវិធីកំណែទម្រង់វិស័យអប់រំ ដែលត្រូវចាប់ផ្តើមពីការអប់រំកុមារតូចឡើងទៅ បើទោះបីជាវាមានតម្រូវពេលវេលាយូរក៏ដោយ ដើម្បីឆ្លើយតបទៅនឹង ផែនការអភិវឌ្ឍជាតិ ក្នុងការទទួលបានកំណើនការងារ សមធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាព នាពេលអនាគត។

### ៤.១.២ ការដឹកនាំគ្រប់គ្រង

#### គោលនយោបាយនៃក្រសួងអប់រំ យុវជន និងកីឡា

គោលនយោបានទី១ *ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* មានគរុសិស្សចំនួន១១៣នាក់បានឆ្លើយត្រឹមត្រូវក្នុងចំណោមគរុសិស្សដែលបំពេញកម្រងសំនួរទាំងអស់១៨៣នាក់។ គោលនយោបានទី២*ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* មានគរុសិស្សចំនួន៥០នាក់បានឆ្លើយត្រឹមត្រូវ ក្នុងចំណោមគរុសិស្សដែលបានបំពេញកម្រងសំនួរទាំងអស់១៨៣នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា គរុ-សិស្សដែលទទួលបានការបណ្តុះបណ្តាល នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ពិតជាមានការយល់ដឹងពីគោលនយោបាយទី១ ប៉ុន្តែមិនទាន់មានការយល់ដឹងពីគោលនយោបាយទី២ទេ ដែលទាមទារឱ្យគណ:គ្រប់គ្រង និងគ្រូឧទ្ទេសត្រូវបញ្ជ្រាបគោលនយោបាយនេះទៅដល់ពួកគេ ព្រោះបើពួកគេមិនយល់សូម្បីតែគោលនយោបាយផង តើពួកគេអាចតម្រង់ទិសសិស្ស ឱ្យឈានទៅសម្រេចគោលនយោបាយ របស់ក្រសួងអប់រំ យុវជន និងកីឡា បានយ៉ាងដូចម្តេចទៅ។ ការមិនយល់ឬមិនបានដឹង អំពីគោលនយោបាយ ឬកម្មវិធីសំខាន់ៗ របស់ក្រសួង សម្រាប់គ្រូឧទ្ទេសនិងគរុសិស្ស ប្រៀបដូចជាការធ្វើដំណើរមិនដឹងមានគោលដៅនោះដែរ។ ដូច្នេះទាមទារឱ្យមាន ការយកចិត្តទុកដាក់បន្ថែមទៀត សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូមួយនេះ ដើម្បីប្រែក្លាយខ្លួន

ទៅជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឈានមុខនិងមានគុណភាពល្អប្រសើរនៅកម្ពុជា។

**កម្មវិធីសំខាន់ទាំង៥របស់ក្រសួងអយក.**

- គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៖ មាន៨៦% ជ្រើសរើសយកចម្លើយបានត្រឹមត្រូវ
- គរុសិស្ស៖ មានតែគរុសិស្ស២០%ប៉ុណ្ណោះ ដែលបានជ្រើសរើសយកចម្លើយត្រឹមត្រូវ គរុសិស្សដែលបានឆ្លើយបានត្រឹមត្រូវនោះមាន៥៦នាក់ ក្នុងចំណោម១៨៣នាក់។

➢ **ចក្ខុវិស័យនិងបេសកកម្មរបស់សាលា**

- **គណៈគ្រប់គ្រង គ្រូឧទ្ទេសនិងគរុសិស្ស**




ចំពោះការលើកឡើងអំពីចក្ខុវិស័យរបស់សាលារៀន មាន៨៦%ផ្តល់ចម្លើយថាបានដឹងសាលាមានចក្ខុវិស័យ និង១៤%ឆ្លើយថាមិនបានដឹងពីចក្ខុវិស័យទេ។ លទ្ធផលនេះជាការល្អមួយ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ព្រោះគ្រូឧទ្ទេសភាគច្រើន បានដឹងពីចក្ខុវិស័យ របស់គ្រឹះស្ថានដែលខ្លួនកំពុងបម្រើការងារ។ តាមរយៈលទ្ធផលនេះ អាចសន្និដ្ឋានបានថា ពួកគេបានចូលរួមបង្កើតនូវចក្ខុវិស័យមួយនេះ ឬមួយក៏ដោយសារគណៈគ្រប់គ្រងបានធ្វើការផ្សព្វផ្សាយ ដល់គ្រូឧទ្ទេសទាំងអស់ ឬមួយមានការបិទបង្ហាញចក្ខុវិស័យនេះ នៅកន្លែងធ្វើការដែលគ្រូឧទ្ទេសនិងគរុសិស្សទាំងអស់ អាចមើលឃើញបាន នៅពេលពួកគេ ចេញចូលក្នុងពេលបំពេញការងារ ឬពេលប្រជុំជាដើម។

- **ផែនការប្រតិបត្តិឆ្នាំ**

គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស




គរុសិស្ស




អំពីផែនការប្រតិបត្តិឆ្នាំ គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៨៦% និងគរុសិស្ស៦១.២% បានឆ្លើយថាដឹង និងគណៈគ្រប់គ្រងនិងគ្រូឧទ្ទេស ឆ្លើយថាមិនបានដឹងទេ មានចំនួន១៤% រីឯគរុសិស្សវិញ ឆ្លើយថាដឹងមានចំនួន៦១.២% និងឆ្លើយថាមិនបានដឹងមានចំនួន៣៨.៨% លទ្ធផលនេះបង្ហាញថា ការរៀបចំផែនការប្រតិបត្តិឆ្នាំ របស់សាលារៀនគឺមានការចូលរួមច្រើន ពីគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស ដែលជាសញ្ញាល្អមួយ សម្រាប់ការអភិវឌ្ឍគ្រឹះស្ថាននេះ ឱ្យមានការរីកចម្រើន ព្រោះថាសាលាគរុកោសល្យដែលល្អ គឺជាសាលារៀនដែលមានគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្សធ្វើកិច្ចសហការគ្នាល្អ និងបង្កើតផែនការរួមគ្នា ហើយអនុវត្តភារកិច្ច ដើម្បីបញ្ជាក់ថាមានការចូលរួម ឬគ្មានការចូលរួម។ ការសិក្សាមួយគួរតែត្រូវបានលើកឡើង ដើម្បីស្វែងយល់ពីលទ្ធផលការអនុវត្តផែនការប្រតិបត្តិឆ្នាំ ថាតើគ្រឹះស្ថានមួយនេះ អនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានលើកឡើងបានប៉ុន្មានភាគរយ ហើយផលសម្រេចបានទាំងនោះ ឆ្លើយតបទៅនឹងចំណុចដៅដែរឬទេ។ បើមិនឆ្លើយតប តើបណ្តាលមកពីបញ្ហាអ្វីខ្លះ ជាឧបសគ្គរាំងស្ទះ វាជាកត្តាខាងក្នុងឬខាងក្រៅកើតឡើងដោយមនុស្ស ឬធម្មជាតិ និងមានការដោះស្រាយបានកម្រិតណា ថ្នាក់ណាជាអ្នកចូលរួម ហើយនៅសេសសល់បញ្ហាអ្វីខ្លះទៀត ដែលមិនទាន់បានដោះស្រាយ ត្រូវការជំនួយពីខាងណា ដើម្បីដោះស្រាយបញ្ហាទាំងនោះបាន។ ម្យ៉ាងវិញទៀត បើអនុវត្តបានជោគជ័យតាមផែនការ តើសាលានឹងត្រូវលើកផែនការប្រតិបត្តិប្រចាំឆ្នាំ បែបណាទៀត ដើម្បីធ្វើឱ្យសាលាមានការអភិវឌ្ឍកាន់តែ ប្រែប្រួលប្លែកពីមួយឆ្នាំទៅមួយឆ្នាំ។

- **គណៈកម្មការទ្រទ្រង់សាលារៀន**




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស នៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ៧៧%បានដឹងថាមានគណៈកម្មការទ្រទ្រង់សាលារៀន។ លទ្ធផលនេះសបញ្ជាក់ឱ្យឃើញថា ដំណើរការឬសកម្មភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀន អាចមានដំណើរការមិនសូវល្អ បានជាគណៈគ្រប់គ្រងសាលានិងគ្រូឧទ្ទេស ឆ្លើយមិនបាន១០០% ថាមានគណៈកម្មការទ្រទ្រង់សាលារៀន ឬអាចនិយាយបានថា គណៈកម្មការទ្រទ្រង់សាលារៀនមានត្រឹមតែរចនាសម្ព័ន្ធ ដែលមិនមានដំណើរការ។

- **ចំនួនគ្រូឧទ្ទេស**



គណៈគ្រប់គ្រងនិងគ្រូឧទ្ទេសៈ មាន៨៥.៧% ផ្តល់ចម្លើយថា សាលាមិនមានគ្រូឧទ្ទេសគ្រប់គ្រាន់ទេ។តាមយោបល់ដែលបានលើកឡើង សាលាមានគណៈកម្មការនិងមានការប្រជុំជាមួយ មាតាបិតាកុមារ។ ចំពោះអ្នកដែលលើកឡើងថា មិនបានដឹងនោះ គឺថាគណៈកម្មការសាលា មិនសូវមានការលើកឡើងពី ការជួយអភិវឌ្ឍសម្រាប់សាលាទាំងមូលនិងគរុសិស្សនោះប៉ុន្មានទេ គឺផ្តោតលើតែកុមារមត្តេយ្យសាលាអនុវត្តភាគច្រើន។

- **មុខវិជ្ជាឯកទេស**




នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានគ្រូឧទ្ទេស៥០% ដែលបានបង្រៀនខុសពីមុខវិជ្ជាឯកទេសរបស់ខ្លួន ដែលនេះជាកត្តាធ្វើឱ្យគុណភាព នៃការបណ្តុះបណ្តាលនៅមានកម្រិត ព្រោះគ្រូបង្រៀនដែមានសមត្ថភាពខ្ពស់ត្រូវឯកទេស ទើបធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្សបានល្អ ឆ្លើយតបទៅនឹងគោលនយោបាយ នៃការអប់រំសកល២០១៥-២០៣០ ដែលសំដៅទៅលើគុណភាពនៃការអប់រំ ជាពិសេសផ្តល់នូវការអប់រំយ៉ាងហោច៩ឆ្នាំប្រកបដោយគុណភាព។ ការបង្រៀនខុសឯកទេស ជាបញ្ហាមួយត្រូវពិចារណាយកចិត្តទុកដាក់ ព្រោះថាការងារដែលមិនមែនជាឯកទេស វាមិនបានផលិតនូវផលដែលល្អត្រឹមត្រូវ មានគុណភាពល្អ មានសុវត្ថិភាពនោះទេ ហើយបើអតិថិជន បានដឹងពីរឿងនេះ ក៏ធ្វើឱ្យពួកគេបាត់បង់នូវការជឿទុកចិត្តចំពោះផលិតផលនោះដែរ និងធ្វើឱ្យពួកគេឈប់លែងជាវផលិតផលនោះផងដែរ។ ដូច្នេះការដែលមានគ្រូឧទ្ទេសបង្រៀនខុសឯកទេសច្រើនរហូតដល់៥០%ភាគរយបែបនេះ នាយកសាលាត្រូវតែលើកឡើងពីបញ្ហានេះ ជម្រាបជូនដល់ថ្នាក់ដឹកនាំ ដោយសង្កត់ធ្ងន់ពីគុណភាពនៃការសិក្សារបស់គរុសិស្សក្នុងគ្រឹះស្ថានបណ្តុះបណ្តាលនេះ ដើម្បីឱ្យថ្នាក់ដឹកនាំរកវិធីជួយដោះស្រាយ។

- **ការលើកទឹកចិត្តបុគ្គលិក**




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស ៨៥.៧% បានផ្តល់ចម្លើយថាមាន និង១៤.៣% បានលើកឡើងថាមិនមាន។ លទ្ធផលនេះឆ្លុះបញ្ចាំងឱ្យឃើញថា ការដឹកនាំរបស់នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានការយកចិត្តទុកដាក់ចំពោះបុគ្គលិកនៅក្រោមការដឹកនាំរបស់ខ្លួន បំពេញបាននូវចំណុចស្តង់ដាជានាយកល្អ។ ព្រោះថាការលើទឹកចិត្តជាវិធីសាស្ត្រខាងចិត្តសាស្ត្រ សម្រាប់ការដឹកនាំនិងគ្រប់គ្រងមនុស្ស ដើម្បីធ្វើឱ្យមនុស្សមានភាពរឹងមាំ លើផ្នែកផ្លូវចិត្ត មានភាពក្លាហានស្វាហាប់ តស៊ូមិនរាថយពុះពារ ព្យាយាមសម្រេចឱ្យបានដល់គោលដៅ ជាអាទិ៍។ ការលើកទឹកចិត្តជាកតាលីករធ្វើឱ្យបុគ្គលិកមានថាមពលបំពេញការងារ មានការទទួលខុសត្រូវនឹងការងារ មានការជឿទុកចិត្តរវាងថ្នាក់ដឹកនាំជាមួយនឹងបុគ្គលិកក្រោមឱវាទ និងការបំពេញការងារ ប្រកបដោយសក្តានុពល នាំឱ្យផលិតបាននូវផលិតផលដែលមានគុណភាពល្អប្រសើរ ហើយក៏ជួយបង្កើតបាននូវភាពជាអ្នកដឹកនាំដល់ខ្លួនឯងផងនិងចំពោះអ្នកដទៃផង សម្រាប់បុគ្គលិកនៅក្នុងគ្រឹះស្ថានរបស់ខ្លួនផងដែរ។ ដូច្នេះការលើកទឹកចិត្ត ជាវិធីសាស្ត្រមួយដែលអ្នកដឹកនាំទាមទារប្រើប្រាស់ជាប្រចាំ ចំពោះបុគ្គលិកដែលបំពេញការងារ ផលិតបាននូវផលិតផលល្អ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន។ ចៀសវាងការលើកទឹកចិត្ត មិនចំអ្នកដែលគួរលើកទឹកចិត្ត ព្រោះថាបើលើកទឹកចិត្តខុសបុគ្គលិក ដែលត្រូវលើកទឹកចិត្តនោះនឹងនាំមកនូវភាពអយុត្តិធម៌ បើមានភាពអយុត្តិធម៌ ការដឹកនាំនឹងមានបញ្ហា។

## ៤.១.៣ ការបង្រៀននិងរៀន

- សម្ភារៈសម្រាប់ដំណើររៀនសូត្រ




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៦៥% ផ្តល់ចម្លើយថាមាន សម្ភារៈបង្រៀននិងរៀនគ្រប់គ្រាន់ និង៣៥% ឆ្លើយថាមិនមានសម្ភារៈបង្រៀននិងរៀនគ្រប់គ្រាន់ទេ។ លទ្ធផលនេះសបញ្ជាក់ថា ការបង្រៀនរបស់គ្រូនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មិនមានការប្រើប្រាស់សម្ភារៈបង្រៀននិងរៀន បានពេញលេញត្រឹមត្រូវទាំងស្រុងទេ សម្រាប់ការបង្រៀន ឬអាចមានគ្រូមួយចំនួនប្រើប្រាស់សម្ភារៈបង្រៀននិងរៀន មានក៏បានគ្មានក៏បាន និងគ្រូមួយចំនួនទៀតព្យាយាមប្រើប្រាស់សម្ភារៈបង្រៀននិងរៀន ឱ្យបានត្រឹមត្រូវនិងពេញលេញដែលនាំឱ្យមានប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន តែសម្ភារៈបង្រៀននិងរៀនទាំងនោះមិនមានគ្រប់គ្រាន់ សម្រាប់បម្រើឱ្យការបង្រៀនរបស់ពួកគាត់និងការរៀន របស់គរុសិស្សទេ។ ដូច្នេះនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម គួរពិនិត្យមើលបញ្ហានេះឡើងវិញ ដើម្បីការបង្រៀនរបស់គ្រូឧទ្ទេសមានប្រសិទ្ធភាព និងការរៀនរបស់គរុសិស្សទទួលបានលទ្ធផលល្អ ព្រោះថាការប្រើប្រាស់សម្ភារៈសម្រាប់បង្រៀននិងរៀនបានជួយឱ្យការបង្រៀននិងរៀន មានភាពស៊ីជម្រៅច្បាស់លាស់ លទ្ធផលនៃការសិក្សារបស់សិស្សមានគុណភាពខ្ពស់ និងមានគុណប្រយោជន៍ សម្រាប់គរុសិស្សយកទៅអនុវត្តបន្តក្នុងការបង្រៀនរបស់ពួកគេ នាពេលពួកគេបានក្លាយជាគ្រូបង្រៀនពិតប្រាកដ នៅតាមមូលដ្ឋានរៀងៗខ្លួនរបស់ពួកគេ។

- **កិច្ចតែងការបង្រៀន សម្ភារឧបទេស**




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៩៧% ផ្តល់ចម្លើយថា គ្រូបង្រៀនមានកិច្ចតែងការ និងប្រើសម្ភារឧបទេសនៅពេលបង្រៀន។ លទ្ធផលនេះសបញ្ជាក់ពីចំណុចល្អប្រសើរ របស់គ្រឹះស្ថានបណ្តុះបណ្តាលក៏ដូចជាគ្រូឧទ្ទេស នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ដែលបំពេញការងាររបស់ខ្លួនគោរពតាម ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន មានចែងនៅត្រង់មាត្រា៨. នៃជំពូកទី២។ កិច្ចតែងការជាសូចនាករមួយដែលមិនអាចខ្វះបាន ក្នុងការវាយតម្លៃការបំពេញការងាររបស់គ្រូ ព្រោះថាគ្រូបង្រៀនដែលបង្រៀនគ្មានកិច្ចតែងការ គឺបង្រៀនសិស្សមិនទទួលបានលទ្ធផលល្អប្រសើរនោះឡើយ។ ម្យ៉ាងទៀតវិញគ្រាន់តែកិច្ចតែងការមិនធ្វើសម្រាប់យកទៅបង្រៀនផងនោះ មិនអាចសង្ឃឹមបានទេថាគ្រូនោះនឹងមានការស្រាវជ្រាវរកវិធីសាស្ត្រថ្មីៗបន្ថែម សម្រាប់បង្រៀនដល់សិស្សនោះ។ ដូច្នេះបើមានគ្រូឧទ្ទេសណាមួយ បង្រៀនសិស្សពុំមានកិច្ចតែងការ ឬមានកិច្ចតែងការដូចគេដែរតែមិនបង្រៀនតាមកិច្ចតែងការ ឬមានតែកិច្ចតែងការដែរតែនោះមិនត្រឹមត្រូវ នាយកសាលាត្រូវធ្វើការណែនាំដល់គាត់ឱ្យធ្វើការងារនេះឡើងវិញ ព្រោះវាជាករណីកិច្ចរបស់គ្រូបង្រៀន ដែលមានចែងក្នុងអនុក្រឹត្យស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ដើម្បីឱ្យគាត់យល់ដឹង និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

- **ប្រើប្រាស់វិធីសាស្រ្តថ្មីៗ**




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៩៦.៧% ផ្តល់ចម្លើយថា គ្រូបានប្រើវិធីសាស្រ្តថ្មីៗ ក្នុងកាបង្រៀនមេរៀនរបស់ខ្លួនដល់សិស្ស។ លទ្ធផលនេះបង្ហាញពីភាពល្អប្រសើរ របស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ដែលមានភាគរយស្ទើរតែមួយរយភាគរយឆ្លើយថាគ្រូឧទ្ទេសបានបង្រៀនមេរៀនរបស់ខ្លួន ដោយមានប្រើវិធីសាស្រ្តថ្មីៗក្នុងការផ្តល់ចំណេះដឹងដល់គរុសិស្ស ដែលនេះក៏ជាចំណុចសំខាន់នៅក្នុងកំណែទម្រង់គុណភាពអប់រំ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ។ ដូច្នេះនាយកសាលាអាចណែនាំបន្ថែម ដល់គ្រូឧទ្ទេសធ្វើការសិក្សាស្រាវជ្រាវជាប្រចាំ នូវវិធីសាស្រ្តដែលថ្មីៗល្អៗសម្រាប់យកមកអនុវត្តក្នុងការបង្រៀន ដល់សិស្សប្រកបដោយលទ្ធផលល្អប្រសើរ។

- **ក្លិបសិក្សា**



គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៨៦.៧% ផ្តល់ចម្លើយថាសាលាមានក្លិបសិក្សា សម្រាប់គរុសិស្សក្នុងការធ្វើស្វ័យសិក្សា ដើម្បីបង្កើនចំណេះដឹងក្រៅពីម៉ោងសិក្សា នៅក្នុងថ្នាក់ជាមួយគ្រូ។ លទ្ធផលនេះបង្ហាញឱ្យឃើញថា គរុសិស្សមានការសិក្សាបន្ថែមជាមួយក្រុមរបស់ខ្លួនលើមុខវិជ្ជានីមួយៗបន្ថែមទៀតក្រៅពីរៀនជាមួយគ្រូ ដើម្បីបំពេញនូវចំណុចមួយចំនួនណាដែលខ្លួនយល់មិនទាន់ច្បាស់ ឱ្យបានយល់ច្បាស់ឡើងវិញឬធ្វើលំហាត់ពង្រីកចំណេះឱ្យកាន់តែបានទូលាយ ។ ប្រការនេះជារឿងល្អសម្រាប់គរុសិស្ស ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យរឹងមាំល្អ តែអាចគរុសិស្សដែលមិនស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន មិនបានអនុវត្តការសិក្សារៀនសូត្របែបនេះ។ បើមិនបានប្រព្រឹត្តដូច្នោះ សាលាមធ្យមសិក្សាត្រូវរកវិធីយ៉ាងណា ដើម្បីពួកគេមានការរៀនសូត្របានដូចគ្នា ព្រោះថាការសិក្សាជាមួយមិត្តភក្តិមានការបំពេញឱ្យគ្នាទៅវិញទៅមកបានល្អផងដែរ។

- **ការសង្កេតថ្នាក់រៀនរបស់នាយក**




គរុសិស្ស៩១.៣% បានផ្តល់ចម្លើយថា នាយកធ្លាប់បានចូលធ្វើការសង្កេតថ្នាក់រៀនរបស់ពួកគេ និងមានតែ៨.៧%ប៉ុណ្ណោះ ដែលឆ្លើយថាមិនធ្លាប់បានឃើញ។ លទ្ធផលនេះសបញ្ជាក់ឱ្យឃើញថា នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម បានបំពេញតួនាទីរបស់ខ្លួនជាអ្នកដឹកនាំនិងគ្រប់គ្រង ដោយមានការពិនិត្យតាមដានលើការអនុវត្តការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីមើលឱ្យឃើញពីចំណុចល្អ និងចំណុចខ្វះចន្លោះរបស់បុគ្គលិក សម្រាប់ធ្វើការលើកសរសើរ និងណែនាំផ្តល់យោបល់លើចំណុចខ្វះចន្លោះទាំងនោះ។

- **លទ្ធផលសិក្សា**




គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស៩៤.០០% បានផ្តល់ចម្លើយថាលទ្ធផលសិក្សារបស់គរុសិស្សមានភាពល្អប្រសើរកើនជាងឆ្នាំសិក្សាកន្លងទៅ និងមានតែ៦.០០%ប៉ុណ្ណោះដែលថាលទ្ធផលសិក្សារបស់គរុសិស្សមិនល្អប្រសើរជាងឆ្នាំមុន។ លទ្ធផលបានបង្ហាញច្បាស់ថាលទ្ធផលសិក្សារបស់គរុសិស្សឆ្នាំទី១ ជំនាន់ទី៣២នេះ មានភាពល្អប្រសើរជាង គរុសិស្សឆ្នាំទី១ ជំនាន់ទី៣១ ដែលជាការប្រៀបធៀបជាមួយគរុសិស្សឆ្នាំទី១ដូចគ្នា តែជំនាន់មុនក្រោយគ្នាមួយជំនាន់។ ដូច្នេះចំណុចវឌ្ឍនភាពមួយ ដែលគ្រឹះស្ថានអប់រំនីមួយៗ ត្រូវតែធ្វើឱ្យមានជាបន្ត ពីឆ្នាំសិក្សាមួយទៅឆ្នាំសិក្សាមួយទៀត ពីជំនាន់មួយទៅជំនាន់មួយទៀត ឱ្យមានភាពប្រសើរឡើងជានិច្ច។

### ៤.១.៤ ផ្នែកហិរញ្ញវត្ថុ

- ប្រាក់អាហារូបករណ៍



គរុសិស្ស៥៧.០០% ឆ្លើយថាបានទទួលប្រាក់អាហារូបត្ថម្ភទៀងទាត់ និង៤២.៦% ឆ្លើយថាមិនទទួលបានទៀងទាត់ទេ។ លទ្ធផលលើចំណុចនេះ មានសភាពមិនល្អទេ ដែលគរុសិស្សមានរហូតដល់៤២.៦% បានឆ្លើយថាការបើកប្រាក់អាហារូបករណ៍ មិនបានទៀងទាត់ វាអាចបង្កឱ្យមានបញ្ហាផ្សេងៗដែលពាក់ព័ន្ធ ជាមួយនឹងប្រាក់អាហារូបករណ៍នេះ ព្រោះថាបើសាលាផ្តល់ឱ្យគរុសិស្សមិនទៀងទាត់ អាចធ្វើឱ្យពួកគាត់មានការលំបាក ក្នុងការដោះស្រាយបញ្ហាខ្លះៗជាមិនខានឡើយ ឬអាចបង្កជាបញ្ហាលំបាកធ្ងន់ធ្ងរក៏ថាបាន។ ដូច្នេះនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវតែចាប់អារម្មណ៍ពីរឿងនេះជាសំខាន់ផងដែរ ដើម្បីស្វែងរកមូលហេតុ និងវិធីដោះស្រាយឱ្យបានច្បាស់សាល់។

### ៤.១.៥ ការស្នាក់នៅរបស់គរុសិស្ស

- **បន្ទប់ស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន**




គរុសិស្ស៩៧.៣% ឆ្លើយថា បន្ទប់ស្នាក់នៅក្នុងអន្តេវាសិកដ្ឋានមិនមានគ្រប់គ្រាន់សម្រាប់គរុសិស្សស្នាក់នៅទេ។ លទ្ធផលនេះបានបង្ហាញច្បាស់ថា អន្តេវាសិកដ្ឋានរបស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានបន្ទប់សម្រាប់គរុសិស្សស្នាក់នៅ មិនគ្រប់គ្រាន់ទេ ដែលជាហេតុធ្វើឱ្យការស្នាក់នៅក្នុងបន្ទប់នីមួយៗ មានចំនួនគរុសិស្ស ច្រើននាក់ ខ្យល់អាកាសចេញចូលមិនសូវល្អ និងអាចបង្កឱ្យមានបញ្ហាសុខភាពដល់គរុសិស្សថែមទៀត។ បើការស្នាក់មិនសូវល្អ ហើយបង្កឱ្យមានបញ្ហាដល់សុខភាពរាងកាយ ទៀនោះនឹងធ្វើឱ្យប៉ះពាល់ដល់ការសិក្សារៀនសូត្ររបស់គរុសិស្សជាប្រាកដ។ ដូច្នេះនាយកសាលាមធ្យមសិក្សគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវធ្វើផែនការជាក់លាក់លើបញ្ហានេះ ដើម្បីឱ្យមានការបណ្តុះបណ្តាលមួយដ៏ល្អប្រសើរ ជាងសព្វថ្ងៃនេះ។

- **ការស្នាក់នៅក្នុងអន្តេវាសិក**

គរុសិស្សទាំងអស់បានលើកឡើងថា ការស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន មានភាពងាយស្រួលក្នុងការសិក្សា មិនចំណាយពេលវេលាក្នុងការធ្វើដំណើរ ជាពិសេសចំពោះដែលគរុសិស្សមកពីខេត្តនានានិងមិនពិបាកស្វែងរកផ្ទះជួលដើម្បីស្នាក់នៅ។

## ៤.២ របកគំហើញ

- គណៈគ្រប់គ្រងនិងគ្រូឧទ្ទេស នៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមភាគច្រើនមានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ តែសមត្ថភាពប្រើប្រាស់នោះភាគច្រើនប្រើបានកម្មវិធីWordមាន៦៩% Powerpointមាន១៥% និង Excellមាន៨% ដូច្នេះអ្នកដែលអាចប្រើបានទាំបីកម្មវិធីWord Powerpoint និង Excell មានតែ៨% ប៉ុណ្ណោះ និងភាសាបរទេសសម្រាប់ការងារ។
- ការដឹកនាំនិងគ្រប់គ្រងរបស់នាយក បានអនុវត្តឆ្លើយតបនឹងចំណុចភាគច្រើន នៃស្តង់ដានាយកសាលា ដូចជា ការរៀបចំឱ្យមានចក្ខុវិស័យ បេសកកម្ម ការធ្វើផែនប្រតិបត្តិប្រចាំឆ្នាំ បានធ្វើការពិនិត្យតាមដានការអនុវត្តការងាររបស់បុគ្គលិក មានការលើកទឹកចិត្តដល់បុគ្គលិក ជាដើម។
- គ្រូឧទ្ទេសមានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ តែមិនទាន់ឆ្លើយតបនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការអប់រំក្នុងកម្រិតបណ្តាប្រទេសអាស៊ានដែរ។ ព្រោះថាបណ្តាប្រទេសក្នុងសមាគមអាស៊ានមួយចំនួនធំ មិននិយាយដល់គ្រូឧទ្ទេសទេ ត្រឹមតែគរុសិស្សកម្រិតមត្តេយ្យសិក្សា គឺគេបានបញ្ចប់កម្រិតបរញ្ញាបត្ររួចអស់ទៅហើយ ចំណែកនៅសាលាមធ្យមសិក្សាគរុកោសល្យមជ្ឈិមនេះវិញ នៅមានគ្រូឧទ្ទេសមួយចំនួនមានសញ្ញាបត្រក្រោមបរិញ្ញាបត្រនៅឡើយ។
- ការបង្រៀនប្រើវិធីសាស្ត្រថ្មីៗបន្ថែម ដែលអាចធ្វើឱ្យគរុសិស្សទទួលបានលទ្ធផលសិក្សាល្អជាងបណ្តាឆ្នាំសិក្សាកន្លងទៅៗ។ ព្រោះថាវីធីសាស្ត្រ វាមានសក្តានុពលខ្លាំង ក្នុងការផ្ទេរឬធ្វើអន្តរកម្មរវាងគ្រូនិងសិស្ស ដើម្បីស្រូបយកឬផលិតនូវចំណេះដឹងរបស់សិស្ស។
- ការប្រើប្រាស់ថវិកាមានតម្លាភាព គឺប្រើប្រាស់ផ្អែកទៅតាមផែនការថវិកា បានលើកឡើង តែនៅមានការខ្វះចន្លោះលើប្រាក់អាហារូបត្ថម្ភរបស់គរុសិស្ស មានការបើកមិនបានទៀងទាត់ដល់គរុសិស្ស ដែលជាបញ្ហាធ្វើឱ្យគរុសិស្ស៩២.៦% បានលើកឡើងពីរឿងនេះ។
- ចំពោះការស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរបស់គរុសិស្ស ទន្ទឹមនឹងចំណុចនៃការគ្រប់គ្រងបានល្អ រក្សាបាននូវសុវត្ថិភាព និងគោរពពេលវេលានៃការសិក្សាបានប្រសើរ ក៏មាន

បញ្ហាមួយចំនួនពាក់ព័ន្ធបរិយាកាសក្នុងបន្ទប់ស្នាក់នៅរបស់គរុសិស្ស មានខ្យល់អាកាស មិនសូវគ្រប់គ្រាន់ល្អ ដោយសារមានចំនួនគរុសិស្សរហូតដល់១៧ ទៅ១៨នាក់ក្នុងមួយ បន្ទប់។

- គ្រូឧទ្ទេសដែលមិនមានបរិញ្ញាបត្រ៣៦% ជាបញ្ហាត្រូវពិចារណា សម្រាប់លោកនាយក ក្នុងការជួយបំពេញសមត្ថភាព តាមរយៈវគ្គបំប៉ន ឬវិក្រិតការ បន្តការសិក្សានៅគ្រឹះស្ថានទីណាខ្លះ ដើម្បីធ្វើឱ្យពួកគាត់បំពេញបានកម្រិតសញ្ញាបត្របរិញ្ញាបត្រ ឬលើសកម្រិតនេះ។
- គ្រូឧទ្ទេសបង្រៀនខុសមុខវិជ្ជាឯកទេសរបស់ខ្លួន មានរហូតដល់៨៥.៧% ដែលជាបញ្ហាចម្បង សម្រាប់នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវពិចារណាដោះស្រាយ ដើម្បីគុណភាពនៃការសិក្សារបស់គរុសិស្ស។ ព្រោះថាការបង្រៀនខុសមុខវិជ្ជាឯកទេសនេះ មិនធ្វើឱ្យគរុសិស្សទទួលបានចំណេះស៊ីជម្រៅល្អនោះទេ។
- កង្វះបន្ទប់ស្នាក់នៅសម្រាប់គរុសិស្ស គឺជាបញ្ហាធំមួយដែរ ដោយសារគរុសិស្សដែលស្នាក់នៅខាងក្រៅអន្តេវាសិកដ្ឋាន មិនទទួលបានពេលវេលាច្រើនដូចអ្នកស្នាក់នៅក្នុងអន្តេវសិកដ្ឋាន លើការសិក្សារៀនសូត្រជាក្លឹមសិក្សានោះទេ។
- ថវិកាសម្រាប់ប្រើប្រាស់ ដើម្បីអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលនេះ ទទួលបានមិនទាន់ឆ្លើយតប ស្របតែជាមួយនឹងផែនការដែលបានស្នើឡើង ដែលជ្រើសរើសយកតែស្ទូចនាករផលសម្រេចចម្បងៗផងនោះ។

ដើម្បីស្វែងយល់លើចំណុចណាមួយជាក់លាក់ និងស៊ីជម្រៅខ្លាំង អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត អាចជ្រើសរើសយកតែចំណុចណាមួយ ដែលអ្នកស្រាវជ្រាវចង់ធ្វើការស្រាវជ្រាវ អំពីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានេះ។ ការស្រាវជ្រាវនេះ មានលក្ខណៈមើលព្រៃទាំងមូល មិនមែនមើលដើមឈើមួយដើមៗទេ ព្រោះថាវាមានលក្ខណៈជាពហុភាព នៃឯកភាពមួយ របស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ដែលមានតែមួយគត់តាំងនៅក្នុងរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍

# ជំពូកទី៥

## ៥. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

### ៥.១. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូ មត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សា គរុកោសល្យមត្តេយ្យមជ្ឈិម មានភាពប្រសើរច្រើន។ នាយកសាលាប្រតិបត្តិតាមមុខងារនិងតួនាទី នៃការដឹកនាំនិងគ្រប់គ្រងរបស់ខ្លួន ដូចជា: មានកសាងនូវចក្ខុវិស័យនិងបេសកកម្មរបស់សាលា បានធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំតាមបែបបទនៃផែនការបច្ចុប្បន្ន បានរៀបចំបំណែងចែកការងារបានត្រឹមត្រូវដល់មន្ត្រី និងគ្រូឧទ្ទេសក្នុងអង្គភាព មានការពិនិត្យតាមដានការអនុវត្តការងាររបស់បុគ្គលិក និងការបង្រៀននិងរៀនរបស់គ្រូឧទេសនិងគរុសិស្ស ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ តែទោះជាយ៉ាងនេះក្តី នាយកសាលាធម្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមត្រូវខិតខំកែលម្អដោយខ្លួនឯង នូវរាល់ចំណុចដែលខ្វះខាតផ្សេងៗ ដោយផ្អែកលើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា កំណែទម្រង់វិស័យអប់រំរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់សកលលោក ដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡា យកមករៀបចំធ្វើជាឯកសារផែនទីបង្ហាញផ្លូវ សម្រាប់អង្គភាពនិងគ្រឹះស្ថានអប់រំនានាយកទៅអនុវត្ត និងរួមជាមួយឯកសារឬគោលការណ៍ផ្សេងទៀតផងដែរ។ ដើម្បីសម្រេចការងារទាំងអស់នេះបាន គឺនាយកសាលាត្រូវមានទំនាក់ទំនងឱ្យបានទូលំទូលាយនិងមានភាពជិតស្និទ ជាមួយបណ្តាអ្នកពាក់ព័ន្ធទាំងអស់នោះ ដើម្បីយល់ដឹងពីគ្នាទៅវិញទៅមកបានច្បាស់លាស់ ងាយស្រួលឱ្យពួកគេសហការជួយដល់គ្រឹះស្ថានបណ្តុះបណ្តាលនេះ ឱ្យមានភាពរីកចម្រើន ឆ្លើយតមនឹងផែនការអភិវឌ្ឍរបស់សាលា។ ដូចជា: ការជួយសម្របសម្រួល ចំពោះគ្រូមួយចំនួនតូច ដែលមិនទាន់មានសញ្ញាបត្របរិញ្ញាបត្រនៅឡើយ អាចមានគ្រឹះស្ថានឧត្តមសិក្សាណាមួយ នឹងជួយផ្តល់ជាអាហារូបករណ៍ដល់ពូកគាត់ ដើម្បីបំពេញបានបរិញ្ញាបត្រ ឬអាចបន្តដល់បរិញ្ញាបត្រជាន់ខ្ពស់ទៀតក៏ថាបាន។ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម នឹងទទួលបាន ថវិកាបន្ថែមទៀត ឆ្លើយតមទៅនឹងតម្រូវការរបស់ខ្លួន ពីរដ្ឋនិងដៃគូរអភិវឌ្ឍដើម្បីប្រែក្លាយគ្រឹះស្ថានមួយនេះ ឱ្យល្អប្រសើរបាន ប្រសិនបើការលើកផែនការអភិវឌ្ឍសាលារៀន មានហេតុផលច្បាស់លាស់ ដើម្បីអះអាងជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៥.២. អនុសាសន៍

ដើម្បីឱ្យសាលា មធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមមួយនេះ ក្លាយជា គ្រឹះស្ថាននណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាមួយ ដែលកាន់តែមានភាពលេចធ្លោឡើងថែមទៀត នោះជាអនុសាសន៍ របស់អ្នកស្រាវជ្រាវ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានេះត្រូវៈ

- ជម្រុញគ្រូដែលមិនមានបរិញ្ញាបត្រទាំងអស់ ឱ្យ ធ្វើការសិក្សាបន្តយកសញ្ញាបត្របរិញ្ញាបត្រ និងឈានទៅរៀនយកសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ថែមទៀតផងដែរ
- ចំពោះគ្រូឧទ្ទេសមានសញ្ញាបត្របរិញ្ញាបត្រ រួចហើយកត្រូវបន្តយកបរិញ្ញាបត្រជាន់ខ្ពស់ និងក៏អាចបន្តយកសញ្ញាបត្របណ្ឌិតផងដែរ ហើយអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់វិញ ក៏គួរបន្តយកសញ្ញាបត្របណ្ឌិតផងដែរ ដើម្បីសាលាមានធនធានសម្បូរបែប សម្រាប់បម្រើការសេវានេះប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើផែនការស្នើផ្តល់គ្រូឧទ្ទេសពីក្រសួងអប់រំ យុវជន និងកីឡា ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ និងត្រូវ ឆ្លើយតមមុខវិជ្ជាដែលជាតម្រូវការរបស់ខ្លួន ដើម្បីជៀសវាងការបង្រៀនខុសមុខវិជ្ជាឯកទេស ច្រើនដូចបច្ចុប្បន្ននេះ
- លើកផែនការសាងសង់អគារស្នាក់សម្រាប់គរុសិស្ស ពីព្រោះការស្នាក់នៅរបស់គរុសិស្សក្នុងបន្ទប់នីមួយៗមានច្រើននាក់ពេក និងក៏មានគរុសិស្សមួយចំនួនទៀតជួនបន្ទប់ស្នាក់នៅក្រៅសាលាផងដែរ ដែលធ្វើឱ្យមានការលំបានក្នុងការគ្រប់គ្រងវិន័យក៏ដូចជាមិនមានឱកាសក្នុងការសិក្សាបន្ថែម ស្របគ្នានឹងអ្នកនៅក្នុងអន្តេវា–សិកដ្ឋាន
- លើកផែនការបង្កើនថវិកា តាមសូចនាករផលសម្រេចសំខាន់ៗ របស់ខ្លួនដែលជាសូចនាករតម្រូវការជាក់លាក់ សម្រាប់ប្រើប្រាស់តាមសកម្មភាពនីមួយៗ ឱ្យឆ្លើយតបនឹងលទ្ធផលរំពឹងទុក និងធ្វើឱ្យ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងមាន នវានុវត្តន៍ជានិរន្តរ៍ពីមួយឆ្នាំទៅមួយឆ្នាំ។

## ឯកសារយោង


1- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

2- ច្បាប់ស្តីពីការអប់រំ ខែធ្នូ ឆ្នាំ២០០៧

3- អនុក្រឹត្យស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ខែកញ្ញា ឆ្នាំ២០០៨

4- គោលនយោបាយសង្ខេបស្តីពីកុមារតូច អង្គការយូណេស្កូ ឆ្នាំ២០០៧

5- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ,ការងារគ្រប់គ្រងរដ្ឋបាល ២០០៩

6- The Education We Want,Unicef Beyond 2015

7- ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១១

8- ប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិត្យការឆ្នាំ២០១៣

9- គោលនយោបាយស្តីពីសាលាកុមារមេត្រីក្រសួងអប់រំយុវជននិងកីឡា ឆ្នាំ២០១២

10-ប្រវត្តិនៃការអប់រំនៅកម្ពុជា លោក យ៉ង់ ធី និងបណ្ឌិត ស៊ិន សំណាង ឆ្នាំ១៩៨៩

11-កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា(១២+២)នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣

12-ការបង្រៀន និងរៀនៈ សម្រេចឱ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា UNESCO ២០១៣-២០១៤

13-Chirsttopher Bessina, et al. no year Partnership Between Schools and Teacher Education Institutes

14-ស្តង់ដានាយកសាលារៀន នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៧

15-ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨

16-ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៨

17-ការអប់រំបរិយាបន្ន សម្រាប់មត្តេយ្យសិក្សា នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៨

18-ការបង្កើតនិងអភិវឌ្ឍន៍ សាលាគរុកោសល្យនៅប្រទេសជប៉ុន Ogawa Yoshikazu សាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា ២០១៨

19-The importance of teaching Department for Education, November 2010

20-សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧ -២០១៨

21-ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា

22-Teacher Training, Teacher Quality, and Student Achievement. Douglas N. Harris and Tim R. Sass Working Paper in version March 12 2008

23-នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ស្តីពីការបណ្តុះបណ្តាលគ្រូបង្រៀន

24-គោលនយោបាយស្តីពីគ្រូបង្រៀន ២៧ ឧសភា ២០១៣

25-Rop Chepkemoi Willitter, OSMAN Ahmed, and KIRUJ J.E. Kipng´etich 2013 Towards Learner Centered Pedagogies by Teacher Educators in Kenya,

26-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤- ២០១៨

27-Economic outcomes and school quality,Jo Anne Anderson Accountability in education 2005

28-អគ្គនាយកដ្ឋានអប់រំ គម្រោងលើកកម្ពស់គុណភាពអប់រំ EEQP

29-គោលនយោបាយស្តីពីសៀវភៅសិក្សាគោល និងមគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោលនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០១២

30-ការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សាសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩

31-ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ.............អយក.វិសព

*ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៥១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**<u>ចម្លងជូន៖</u>**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-សាលារាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ: ១១៩ វជអ.ភក**

**លិខិតឧទ្ទេសនាម**

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ ភ័ទ្បង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអឿល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ជ៉ែត ភ័ក្រ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណាក់ | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្ដិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាវស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈឿន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រ៊ី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណូ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្ដរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីរដ្ឋ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណរ៉ា**

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# កម្រងសំណួរ
# សម្រាប់គណៈគ្រប់គ្រងសាលា

ខ្ញុំបាទឈ្មោះ **ឆន ឈាង** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំបានជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវ **"ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា "** ដែលជ្រើសយកករណីសិក្សានៅ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យសិក្សាមជ្ឈិម មកធ្វើការសិក្សា។ ដូច្នេះស្នើ លោកនាយក លោកស្រីនាយិការង មេត្តាជួយផ្តល់ឆ្លើយ តាមកម្រង សំណួរបន្តបន្ទាប់មាននៅខាងក្រោមនេះ ហើយ រាល់ចម្លើយរបស់លោក លោកស្រី នឹងត្រូវបានរក្សាជាការសម្ងាត់ខ្ពស់បំផុត ដោយ ចម្លើយទាំងនោះយកប្រើប្រាស់សម្រាប់តែការសរសេរនិក្ខេបបទនេះតែប៉ុណ្ណោះ។

**ផ្នែកទី១ ៖ ព័ត៌មានទូទៅ**

សូមលោក លោកស្រី ជួយបំពេញចម្លើយដោយគូសសញ្ញា(√) និងសរសេរបំពេញនៅចំណុចដែលចន្លោះនីមួយៗទាំងនោះ។

១. ភេទ: ប្រុស □ ស្រី □

២.អាយុ..............ឆ្នាំ

៣. តួនាទី □ នាយក □ នាយក/នាយិការង

៤.កម្រិតបណ្តុះបណ្តាលវិជ្ជាជីវ:......................................ឯកទេស.....................

៥. កម្រិតបណ្តុះបណ្តាលថ្នាក់ចុងក្រោយ:.....................................................................

៦. ភាសាបរទេស:.......................................... □មធ្យម □ល្អ □ល្អប្រសើរ

៧.កុំព្យូទ័រ: □ អាចកម្មវិធីWord បាន □ អាចប្រើកម្មវិធី Excel □ អាចប្រើកម្មវិធី PowerPoint

៨.រយៈពេលបំពេញការងារ: តិចជាង □ ៥ឆ្នាំ □ ៦-១៥ឆ្នាំ □ ច្រើនជាង១៥ឆ្នាំ

**ផ្នែកទី២ ៖ ការដឹកនាំគ្រប់គ្រង**

១.ក្រសួងអយក. បានខិតខំអនុវត្តការងារគ្រប់បែបយ៉ាង ដើម្បីបម្រើឱ្យគោលនយោបាយរបស់ខ្លួន តើខាងក្រោមនេះចំណុចណាខ្លះ ដែលជាគោលនយោបាយ នៃក្រសួងអយក.?

□ ក.កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

□ ខ.ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់

ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

□ គ.ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

□ ឃ.ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

□ ង.ការរៀបចំកន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា

២. ក្រសួងអយក.បាននិងកំពុងអនុវត្តកម្មវិធីសំខាន់ៗចំនួន៥ តាមរយៈកំណែទម្រង់ដែលបានកំណត់ ដើម្បីឆ្លើយតបនឹងគោលនយោបាយរបស់ខ្លួន។ ខាងក្រោមនេះ ជាកម្មវិធីសំខាន់ៗទាំង៥នោះ តើសាលារបស់អ្នកបាននិងកំពុងអនុវត្តលើកម្មវិធីមួយណា?

□ ក.កម្មវិធីទី១ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

□ ខ.កម្មវិធីទី២ ការអភិវឌ្ឍឧត្តមសិក្សានិងស្រាវជ្រាវ

□ គ.កម្មវិធីទី៣ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

□ ឃ.កម្មវិធីទី៤ ការអភិវឌ្ឍជំនាញទន់ បច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

□ ង.កម្មវិធីទី៥ ការគាំទ្រសេវាអប់រំនិងអភិបាលកិច្ចល្អ.

៣.តើសាលាអ្នកមានចក្ខុវិស័យនិងបេសកកម្មទេ? □គ្មាន □មាន □គ្រប់គ្នាដឹង

៤.ដើម្បីសម្រេចនូវចក្ខុវិស័យនិងបេសកកម្មខាងលើ តើសាលាអ្នកបាន កំណត់យុទ្ធសាស្ត្រទេ?

□គ្មាន □មាន បើបានកំណត់ តើយុទ្ធសាស្ត្រទាំងនោះមានអ្វីខ្លះ?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៥.តើសាលាអ្នកមានផែនការប្រតិបត្តិទេ? □គ្មាន □មាន បើមានតើបានអនុវត្តដូចម្តេចដែរ? មានបញ្ហាអ្វីរាំងស្ទះទេ?...........................................................................

..................................................................................................................................

..........................................................................................................................

៦.តើសាលាអ្នកមានគណៈកម្មការទ្រទ្រង់សាលាដែរទេ? □គ្មាន □មាន

បើមានបានជួយអ្វីខ្លះដល់សាលា..................................................................................

...............................................................................................................................

៧.តើសាលាអ្នកមានគ្រូឧទ្ទេសគ្រប់គ្រាន់ទេ? □មិនគ្រប់ទេ □មានគ្រប់

៨.តើគ្រូឧទ្ទេសទាំងអស់ បង្រៀនត្រូវតាមមុខវិជ្ជាឯកទេសទេ ឬមានគ្រូឧទ្ទេសខ្លះបង្រៀនខុស មុខវិជ្ជាឯកទេសរបស់ខ្លួន? □ខុសឯកទេសខ្លះ □ត្រូវចំឯកទេសទាំងអស់

៩.តើសាលាអ្នកមានការវាយតម្លៃនិងលើកទឹកចិត្តដល់បុគ្គលិកដែលមានស្នាដៃល្អដែរទេ? □គ្មាន □មាន បើមានតើជាស្នាដៃអ្វីនិងការលើកទឹកចិត្តនោះ ដោយផ្តល់ឱ្យនូវអ្វី?....................................................................................

....................................................................................................

....................................................................................................

១០. តើអ្នកមានបំណងចង់ធ្វើអ្វីដែលសំខាន់បំផុត សម្រាប់អភិវឌ្ឍសាលាអ្នក? នៅពេលណា?....................................................................................

....................................................................................................

**ផ្នែកទី៣ ៖ការបង្រៀននិងរៀន**

១.តើសាលាអ្នកមានសម្ភារៈ សម្រាប់ដំណើរការបង្រៀននិងរៀនគ្រប់គ្រាន់ទេ? □គ្មាន/មានមិនគ្រប់ □មានគ្រប់គ្រាន់ បើគ្មាន/មានមិនគ្រប់ តើសម្ភារៈអ្វីខ្លះដែលសំខាន់បំផុត អ្នកចង់បានមុនគេ?

....................................................................................................

....................................................................................................

២.តើគ្រូធ្វើកិច្ចតែងការបង្រៀន មានសម្ភារឧបទេស និងបានប្រើរបស់ទាំងនេះទេ? □ គ្មាន/មានមិនប្រើ □មានបានប្រើ ចំណែកបុគ្គលិកមិនបង្រៀន តើពួកគាត់មានធ្វើផែនការការងារផ្ទាល់ខ្លួនទេ? □ គ្មាន □មាន

៣. ដើម្បីឱ្យការបង្រៀនប្រកបដោយប្រសិទ្ធភាព តើអ្នកមានបានស្រាវជ្រាវនិងប្រើប្រាស់វិធីសាស្រ្តល្អថ្មីៗ សម្រាប់បង្រៀនដែរទេ? □ គ្មាន □មាន បើមានសុំផ្តល់ជាឧទាហរណ៍តើវិធីសាស្រ្តអ្វីខ្លះ?....................................

....................................................................................................

....................................................................................................

៤.តើសាលារបស់អ្នក មានរៀចំក្លិបសិក្សាសម្រាប់គរុសិស្ស និងបានប្រតិបត្តិជាប្រចាំដែរទេ? □ គ្មាន □មាន និងបានប្រតិបត្តិជាប្រចាំ

៥.ប្រសិនការបង្រៀនជួបប្រទះនឹងសិស្សរៀនយឺតឬខ្សោយ តើសាលាបានជួយសិស្សដូចម្ដេច?

............................................................................................................................................

............................................................................................................................................

៦.តើក្នុងឆ្នាំសិក្សានេះ សាលាមានធ្វើការសង្កេតការបង្រៀននិងផ្ដល់អនុសាសន៍ដល់គ្រូឧទ្ទេសទាំងអស់ដែរឬទេ? □ មិនមានទេ/មានខ្លះ □មានទាំងអស់

៧.តើលទ្ធផលសិក្សារបស់គរុសិស្សជារួមក្នុងឆ្នាំសិក្សានេះ មានភាពល្អប្រសើរជាងឬមានភាពខ្សោយជាងឆ្នាំកន្លងទៅ? □ខ្សោយជាង □ល្អជាង

**ផ្នែកទី៤ ៖ ផ្នែកហិរញ្ញវត្ថុ**

១.តើថវិកាដែលរដ្ឋបានផ្ដល់ឱ្យសាលា សម្រាប់យកទៅប្រតិបត្តិការងារផលិតបានលទ្ធផលឆ្លើយតបផែនការឬទេ? □ មិនឆ្លើយតបទេ □ឆ្លើយតប បើមិនឆ្លើយតបហេតុអ្វី?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

២.តើសាលាអ្នកមានប្រភពថវិកាផ្សេងណាខ្លះទៀតទេ?

............................................................................................................................................

............................................................................................................................................

៣.តើការប្រើប្រាស់និងទូទាត់ថវិកាសម្រាប់សាលារបស់អ្នក បង្ហាញគណនេយ្យភាពចំពោះ គ្រប់អ្នកពាក់ព័ន្ធទេ? □ មិនមានគណនេយ្យភាពទេ □មានគណនេយ្យភាព បើទោះមិនមានឬមានគណនេយ្យភាព តើអ្នកបានអនុវត្តដូចម្ដេច?

............................................................................................................................................

............................................................................................................................................

**ផ្នែកទី៥ ៖ ការស្នាក់នៅរបស់គរុសិស្ស**

១. តើអន្តេវាសិកដ្ឋានសាលារបស់អ្នក មានបន្ទប់ស្នាក់នៅ សម្រាប់គរុសិស្សគ្រប់គ្រាន់ដែរទេ? □មិនគ្រប់ទេ □គ្រប់គ្រាន់ បើមិនគ្រប់អ្នកបានដោះស្រាយយ៉ាងដូចម្ដេច? □មិនបានដោះទេ □បានដោះស្រាយដោយប្រើថវិការដ្ឋជួលផ្ទះ ឱ្យគរុសិស្សស្នាក់នៅ

២. ចំពោះគរុសិស្សដែលស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរបស់សាលា តើមានភាពងាយស្រួលនិងការលំបាកយ៉ាងដូចម្តេចដែរ?

........................................................................................................................................

........................................................................................................................................

៣.បើមានគរុសិស្សស្នាក់ នៅ ខាងក្នុងផងនិងក្រៅសាលាផង តើអ្នកមានការកត់សម្គាល់ឃើញអ្វីជាសំខាន់ រវាងគរុសិស្សស្នាក់នៅក្នុងសាលា និងគរុសិស្សថ្នាក់ នៅក្រៅសាលា? (ផ្តោតលើពេលវេលា ឥរិយាបថក្នុងការសិក្សា...)

........................................................................................................................................

........................................................................................................................................

........................................................................................................................................

*សូមអរគុណជាអនេកចំពោះ ការចំណាយពេលវេលាបំពេញកម្រងសំណួរទាំងនេះ !*

# កម្រងសំណួរ
# សម្រាប់គ្រូឧទ្ទេស

ខ្ញុំបាទឈ្មោះ **ឆន ឈាង** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំបានជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវ **"ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា "** ដែលជ្រើសយកករណីសិក្សា សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យសិក្សាមជ្ឈិម មកធ្វើការសិក្សា។ ដូច្នេះស្នើ លោកគ្រូ អ្នកគ្រូឧទ្ទេសទាំងអស់ មេត្តាជួយផ្តល់ឆ្លើយ តាមកម្រង សំណួរបន្តបន្ទាប់ ដែលមាននៅ ខាងក្រោមនេះ ហើយ រាល់ចម្លើយរបស់លោក លោកស្រី នឹងត្រូវបានរក្សាជាការសម្ងាត់ខ្ពស់បំផុត ដោយចម្លើយទាំងនោះ យកប្រើប្រាស់សម្រាប់តែការសរសេរនិក្ខេបបទនេះតែប៉ុណ្ណោះ។

## ផ្នែកទី១ ៖ ព័ត៌មានទូទៅ

សូមលោកគ្រូ អ្នកគ្រូឧទ្ទេស ជួយ បំពេញចម្លើយដោយគូសសញ្ញា(√) និងសរសេរបំពេញនៅចំណុចដែលចន្លោះនីមួយៗទាំងនោះ។

១. ភេទ: ប្រុស ☐ ស្រី ☐

២.អាយុ..............ឆ្នាំ

៣. កម្រិតបណ្តុះបណ្តាលវិជ្ជាជីវ:.................................ឯកទេស..........................

៤. សព្វថ្ងៃបង្រៀនមុខវិជ្ជា:.........................................................................

៥. កម្រិតបណ្តុះបណ្តាលថ្នាក់ចុងក្រោយ:.......................................................

៦. ភាសាបរទេស:...........................................☐មធ្យម ☐ល្អ ☐ល្អប្រសើរ

៧.កុំព្យូទ័រ: ☐ អាចកម្មវិធីWord បាន ☐ អាចប្រើកម្មវិធី Excel ☐ អាចប្រើកម្មវិធី PowerPoint

៨.រយៈពេលបំពេញការងារ: តិចជាង ☐ ៥ឆ្នាំ ☐ ៦-១៥ឆ្នាំ ☐ ច្រើនជាង១៥ឆ្នាំ

## ផ្នែកទី២ ៖ ការដឹកនាំគ្រប់គ្រង

១.ក្រសួងអយក. បានខិតខំអនុវត្តការងារគ្រប់បែបយ៉ាង ដើម្បីបម្រើឱ្យគោលនយោបាយរបស់ខ្លួន តើខាងក្រោមនេះចំណុចណាខ្លះ ដែលជាគោលនយោបាយនៃក្រសួងអយក.?

☐ ក.កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

☐ ខ.ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់

ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

□ គ.ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

□ ឃ.ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

□ ង.ការរៀបចំកន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា

២. ក្រសួងអយក.បាននិងកំពុងអនុវត្តកម្មវិធីសំខាន់ៗចំនួន៥ តាមរយៈកំណែទម្រង់ដែលបានកំណត់ ដើម្បីឆ្លើយតបនឹងគោលនយោបាយរបស់ខ្លួន។ ខាងក្រោមនេះជាកម្មវិធីសំខាន់ៗទាំង៥នោះ តើសាលារបស់អ្នកបាននិងកំពុងអនុវត្តលើកម្មវិធីមួយណា?

□ ក.កម្មវិធីទី១ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

□ ខ.កម្មវិធីទី២ ការអភិវឌ្ឍឧត្តមសិក្សានិងស្រាវជ្រាវ

□ គ.កម្មវិធីទី៣ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

□ ឃ.កម្មវិធីទី៤ ការអភិវឌ្ឍជំនាញទន់ បច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

□ ង.កម្មវិធីទី៥ ការគាំទ្រសេវាអប់រំនិងអភិបាលកិច្ចល្អ.

៣.តើលោកគ្រូ អ្នកគ្រូឧទ្ទេស ដឹងថាសាលាមានចក្ខុវិស័យនិងបេសកកម្មទេ?

□មិនដឹង □ដឹង

៤.ដើម្បីសម្រេចនូវចក្ខុវិស័យនិងបេសកកម្មខាងលើ តើសាលាមានកំណត់យុទ្ធសាស្ត្រទេ?

□គ្មាន □មាន បើបានកំណត់ តើយុទ្ធសាស្ត្រទាំងនោះមានអ្វីខ្លះ?

.............................................................................................................................

.............................................................................................................................

៥.តើសាលារបស់លោកគ្រូ អ្នកគ្រូ មានផែនការប្រតិបត្តិប្រចាំឆ្នាំទេ? □គ្មាន □មាន បើមានតើបានអនុវត្តដូចម្តេចដែរ? មានបញ្ហាអ្វីរាំងស្ទះទេ?............................................

.............................................................................................................................

៦.តើសាលារបស់លោកគ្រូ អ្នកគ្រូ មានគណៈកម្មការទ្រទ្រង់សាលាដែរទេ?

□គ្មាន □មាន បើមានបានជួយអ្វីខ្លះដល់សាលា.........................................................

.............................................................................................................................

៧.តើសាលាអ្នកមានគ្រូឧទ្ទេសគ្រប់គ្រាន់ទេ? ☐មិនគ្រប់ទេ ☐មានគ្រប់

៨.តើអ្នកបង្រៀនត្រូវតាម មុខវិជ្ជាឯកទេសរបស់អ្នកទេ? ☐មិនត្រូវទេ ☐ត្រូវឯកទេស

៩.តើសាលាអ្នកមានការវាយតម្លៃ និងលើកទឹកចិត្តដល់បុគ្គលិក ដែលមានស្នាដៃល្អដែរទេ? ☐គ្មាន ☐មាន បើមានតើជាស្នាដៃអ្វីនិងការលើកទឹកចិត្តនោះដោយផ្តល់ឱ្យនូវអ្វី?

..........................................................................................................................................

..........................................................................................................................................

១០. តើអ្នកមានបំណងចង់ធ្វើអ្វីដែលសំខាន់បំផុត សម្រាប់អភិវឌ្ឍសាលាអ្នក? នៅពេលណា?...............................................................................................................

..........................................................................................................................................

**ផ្នែកទី៣ ៖ការបង្រៀននិងរៀន**

១.តើសាលាអ្នកមានសម្ភារៈ សម្រាប់ដំណើរការបង្រៀននិងរៀនគ្រប់គ្រាន់ទេ? ☐គ្មាន/មានមិនគ្រប់ ☐មានគ្រប់គ្រាន់ បើគ្មាន/មានមិនគ្រប់ តើសម្ភារៈអ្វីខ្លះដែលសំខាន់បំផុត អ្នកចង់បានមុនគេ? ..................................................................................................

..........................................................................................................................................

២.តើអ្នកមានកិច្ចតែងការបង្រៀន សម្ភារឧបទេស និងបានប្រើរបស់ទាំងនេះទេពេលបង្រៀន? ☐ គ្មាន/មិនប្រើ ☐មានបានប្រើ តែបើអ្នកជាបុគ្គលិកមិនបង្រៀន តើអ្នកមានធ្វើផែនការការងារផ្ទាល់ខ្លួនទេ? ☐ គ្មាន ☐មាន

៣. ដើម្បីឱ្យការបង្រៀនប្រកបដោយប្រសិទ្ធភាព តើគ្រូឧទ្ទេសមានបានស្រាវជ្រាវ និងប្រើប្រាស់វិធីសាស្ត្រល្អថ្មីៗ សម្រាប់បង្រៀនដែរទេ? ☐ គ្មាន ☐មាន បើមានសុំផ្តល់ជាឧទាហរណ៍តើវិធីសាស្ត្រអ្វី?.........................................................................................

..........................................................................................................................................

៤.តើសាលារបស់អ្នក មានរៀបចំក្លិបសិក្សាសម្រាប់គរុសិស្ស និងបានប្រតិបត្តិជាប្រចាំដែរទេ? ☐ គ្មាន ☐មាននិងបានប្រតិបត្តិជាប្រចាំ

៥.ប្រសិនការបង្រៀនជួបប្រទះនឹងសិស្សរៀនយឺតឬខ្សោយ តើសាលាបានជួយសិស្សដូចម្តេច?...............................................................................................................

..........................................................................................................................................

៦.តើក្នុងឆ្នាំសិក្សានេះ សាលាមានធ្វើការសង្កេតការបង្រៀននិងផ្តល់អនុសាសន៍ដល់គ្រូឧទ្ទេសទាំងអស់ដែរឬទេ? □ មិនមានទេ/មានខ្លះ □មានទាំងអស់

៧.តើលទ្ធផលសិក្សារបស់គរុសិស្សជារួមក្នុងឆ្នាំសិក្សានេះ មានភាពល្អប្រសើរជាងឬមានភាពខ្សោយជាងឆ្នាំកន្លងទៅ? □ខ្សោយជាង □ល្អជាង

**ផ្នែកទី៤ ៖ ផ្នែកហិរញ្ញវត្ថុ**

១.តើថវិកាដែលរដ្ឋបានផ្តល់ឱ្យសាលា សម្រាប់យកទៅប្រតិបត្តិការងារផលិតបានលទ្ធផលឆ្លើយតបផែនការឬទេ? □ មិនឆ្លើយតបទេ □ឆ្លើយតប បើមិនឆ្លើយតបហេតុអ្វី?..........................................................................................

..............................................................................................................

២.តើសាលាអ្នកមានប្រភពថវិកាផ្សេងណាខ្លះទៀតទេ? .....................................

..............................................................................................................

៣.តើការប្រើប្រាស់ថវិកាសម្រាប់សាលារបស់អ្នក បង្ហាញពីគណនេយ្យភាពទេ?

□ មិនមានគណនេយ្យភាពទេ □មានគណនេយ្យភាព

យោបល់:...................................................................................................

..............................................................................................................

**ផ្នែកទី៥ ៖ ការស្នាក់នៅរបស់គរុសិស្ស**

១. តើអន្តេវាសិកដ្ឋានសាលារបស់អ្នក មានបន្ទប់ស្នាក់នៅ សម្រាប់គរុសិស្សគ្រប់គ្រាន់ដែរទេ? □មិនគ្រប់ទេ □គ្រប់គ្រាន់ បើមិនគ្រប់អ្នកបានដោះស្រាយយ៉ាងដូចម្តេច? □មិនបានដោះទេ □បានដោះស្រាយដោយប្រើថវិការដ្ឋជួលផ្ទះឱ្យគរុសិស្សស្នាក់នៅ។

២. ចំពោះគរុសិស្សដែលស្នាក់នៅ ក្នុងអន្តេវាសិកដ្ឋានរបស់សាលា តើមានភាពងាយស្រួលនិងការលំបាកយ៉ាងដូចម្តេចដែរ? ..........................................................

..............................................................................................................

៣.បើមានគរុសិស្សស្នាក់នៅ ខាងក្នុងផងនិងក្រៅសាលាផង តើអ្នកមានការកត់សម្គាល់ឃើញអ្វីជាសំខាន់ រវាងគរុសិស្សស្នាក់នៅក្នុងសាលា និងគរុសិស្សថ្នាក់នៅក្រៅសាលា? (ផ្តោតលើពេលវេលា ឥរិយាបថក្នុងការសិក្សា...)

..............................................................................................................

..............................................................................................................

*សូមអរគុណជាអនេកចំពោះ ការចំណាយពេលវេលាបំពេញកម្រងសំណួរទាំងនេះ !*

# កម្រងសំណួរ
# សម្រាប់គរុសិស្ស

ខ្ញុំបាទឈ្មោះ **ធន ឈាង** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំបានជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវ **"ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា "** ដែលជ្រើសយកករណីសិក្សានៅ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យសិក្សាមជ្ឈិម មកធ្វើការសិក្សា។ ដូច្នេះស្នើប្អូនៗជាគរុសិស្សគ្រប់គ្នា មេត្តាជួយផ្តល់ឆ្លើយ តាមកម្រង សំណួរបន្តបន្ទាប់មាននៅខាងក្រោមនេះ ហើយ រាល់ចម្លើយរបស់ប្អូនៗ នឹងត្រូវបានរក្សាជាការសម្ងាត់ខ្ពស់បំផុត ដោយ ចម្លើយទាំងនោះយកប្រើប្រាស់សម្រាប់តែការសរសេរនិក្ខេបបទនេះតែប៉ុណ្ណោះ។

**ផ្នែកទី១ ៖ ព័ត៌មានទូទៅ**

សូមលោក លោកស្រី ជួយ បំពេញចម្លើយដោយគូសសញ្ញា(√) និងសរសេរបំពេញនៅចំណុចដែលចន្លោះនីមួយៗទាំងនោះ។

១. ភេទ: ប្រុស ☐ ស្រី ☐

២.អាយុ..............ឆ្នាំ

៣.ភាសាបរទេស:...............................☐មធ្យម ☐ល្អ ☐ល្អប្រសើរ

៤. កុំព្យូទ័រ: ☐ អាចកម្មវិធីWord បាន ☐ អាចប្រើកម្មវិធី Excel ☐ អាចប្រើកម្មវិធី PowerPoint

៥. គរុសិស្សជំនាន់ទី..........................................................................................

**ផ្នែកទី២ ៖ ការដឹកនាំគ្រប់គ្រង**

១.ក្រសួងអយក. បានខិតខំអនុវត្តការងារគ្រប់បែបយ៉ាង ដើម្បីបម្រើឱ្យគោលនយោ–បាយរបស់ខ្លួន តើខាងក្រោមនេះចំណុចណាខ្លះ ដែលជាគោលនយោបាយនៃក្រសួងអយក.?

☐ ក.កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

☐ ខ.ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

☐ គ.ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

☐ ឃ.ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

□ ង.ការរៀបចំកន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា

២. ក្រសួងអយក.បាននិងកំពុងអនុវត្តកម្មវិធីសំខាន់ៗចំនួន៥ តាមរយៈកំណែទម្រង់ដែលបានកំណត់ ដើម្បីឆ្លើយតបនឹងគោលនយោបាយរបស់ខ្លួន។ ខាងក្រោមនេះជាកម្មវិធីសំខាន់ៗទាំង៥នោះ តើសាលារបស់អ្នកបាននិងកំពុងអនុវត្តលើកម្មវិធីមួយណា?

□ ក.កម្មវិធីទី១ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

□ ខ.កម្មវិធីទី២ ការអភិវឌ្ឍឧត្តមសិក្សានិងស្រាវជ្រាវ

□ គ.កម្មវិធីទី៣ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

□ ឃ.កម្មវិធីទី៤ ការអភិវឌ្ឍជំនាញទន់ បច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

□ ង.កម្មវិធីទី៥ ការគាំទ្រសេវាអប់រំនិងអភិបាលកិច្ចល្អ.

៣.តើអ្នកបានយល់ដឹងពីចក្ខុវិស័យនិងបេសកកម្មរបស់សាលាទេ? □មិនដឹងទេ □បានដឹង

៤.ដើម្បីសម្រេចនូវចក្ខុវិស័យនិងបេសកកម្មខាងលើ តើអ្នកដឹងពីយុទ្ធសាស្ត្រ ដែលសាលាបានកំណត់ទេ? □មិនដឹងទេ □បានដឹង បើបានដឹង សូមលើឡើងឱ្យបានមួយចំណុចជាឧទាហរណ៍:..................................................................................................

..............................................................................................................................

៥.តើអ្នកបានដឹងថាសាលាមានផែនការប្រតិបត្តិទេ? □មិនដឹងទេ □បានដឹង

៦.តើអ្នកអ្នកបានដឹងថា សាលាមានគណៈកម្មការទ្រទ្រង់ដែរទេ? □មិនដឹងទេ □បានដឹង បើបានដឹង តើមានឃើញលទ្ធផលអ្វីខ្លះ ដែលគណៈកម្មការនោះសម្រេចបាន ចូរលើជាឧទាហរណ៍:...........................................................................................................

..............................................................................................................................

៧.តើសាលាអ្នកមានគ្រូឧទ្ទេសគ្រប់គ្រាន់ទេ? □មិនគ្រប់ទេ □មានគ្រប់

៨.តើគ្រូឧទ្ទេសទាំងអស់របស់អ្នក បង្រៀនត្រូវតាមមុខវិជ្ជាឯកទេសរបស់ពួកគាត់ទេ? □ខុសឯកទេសខ្លះ □ត្រូវចំឯកទេសទាំងអស់

៩.តើអ្នកដឹងថាសាលា មានការវាយតម្លៃនិងលើកទឹកចិត្ត ដល់បុគ្គលិកទាំងអស់រួមទាំងគរុសិស្សដែលមានស្នាដៃល្អដែរទេ? □គ្មាន □មាន បើមានតើជាស្នាដៃអ្វី និងការលើកទឹកចិត្តនោះដោយផ្តល់ឱ្យនូវអ្វី?.....................................................................

..............................................................................................................................

១០. បើអ្នកមានលទ្ធភាព តើអ្នកចង់ធ្វើអ្វីដែលសំខាន់បំផុត សម្រាប់អភិវឌ្ឍសាលារបស់អ្នក? នៅពេលណា? ..........................................................................................

..........................................................................................................

**ផ្នែកទី៣ ៖ការបង្រៀននិងរៀន**

១.តើសាលាអ្នកមានសម្ភារៈ សម្រាប់ដំណើររៀនសូត្ររបស់អ្នកទេ □គ្មាន/មានមិនគ្រប់ □មានគ្រប់គ្រាន់ បើគ្មាន/មានមិនគ្រប់ តើសម្ភារៈអ្វីខ្លះដែលសំខាន់បំផុត អ្នកចង់បានមុនគេ? ..........................................................................................

..........................................................................................................

២.តើគ្រូមានកិច្ចតែងការបង្រៀន សម្ភារឧបទេស និងបានប្រើរបស់ទាំងនោះ សម្រាប់បង្រៀនដល់អ្នកទេ? □ គ្មាន/មានមិនប្រើ □មាននិងបានប្រើ

៣. ដើម្បីឱ្យការបង្រៀនប្រកបដោយប្រសិទ្ធភាព តើគ្រូឧទ្ទេសមានបានប្រើប្រាស់វិធីសាស្រ្តថ្មីៗ អ្វីខ្លះ សម្រាប់បង្រៀនដែរទេ? □ គ្មាន □មាន បើមានសុំផ្តល់ជាឧទាហរណ៍តើវិធីសាស្រ្តអ្វីខ្លះ?..........................................................................

..........................................................................................................

៤.ក្រៅពីរៀនតាមកាលវិភាគប្រចាំថ្ងៃ តើអ្នកក្លិបសិក្សាសម្រាប់រៀនបន្ថែមទៀតទេ? □ គ្មាន □មាននិងរៀនជាប្រចាំ

៥.នៅជំនាន់របស់អ្នក មានសិស្សរៀនយឺតឬខ្សោយទេ? □ គ្មាន □មាន បើមានតើសាលាបានជួយពួកគេដូចម្តេច?..........................................................................

..........................................................................................................

៦.តើអ្នកធ្លាប់ឃើញលោកនាយក ចូលធ្វើការសង្កេតការបង្រៀននៅថ្នាក់រៀនរបស់អ្នកទេ? □ គ្មានទេ □មាន

៧.តើលទ្ធផលសិក្សារបស់អ្នកក្នុងឆ្នាំសិក្សានេះ មានភាពល្អប្រសើរជាង ឬមានភាពខ្សោយជាងឆ្នាំកន្លងទៅ? □ខ្សោយជាង □ល្អជាង

**ផ្នែកទី៤ ៖ ផ្នែកហិរញ្ញវត្ថុ**

១.តើការបើកប្រាក់អាហារូបករណ៍ របស់អ្នកបានទៀងទាត់ទេ? □ មិនទៀងទេ □ទៀងយោបល់..........................................................................

..........................................................................................................

២.តើអ្នកទទួលបានប្រាក់ពីប្រភពណាផ្សេងទៀតង សម្រាប់ចំណាយក្នុងការសិក្សានេះទេ? ..........................................................................................................................
..........................................................................................................................................

៣.តើចំណាយរបស់អ្នកសម្រាប់មួយខែៗ អាចចាយគ្រប់ល្មម ឬមានការលំបាកដូចម្ដេចខ្លះដែរ? ...................................................................................................................
..........................................................................................................................................

**ផ្នែកទី៥ ៖ ការស្នាក់នៅរបស់គរុសិស្ស**

១. តើអន្តេវាសិកដ្ឋានសាលារបស់អ្នក មានបន្ទប់ស្នាក់នៅសម្រាប់គរុសិស្សគ្រប់គ្រាន់ដែរទេ? ☐មិនគ្រប់ទេ ☐គ្រប់គ្រាន់ បើមិនគ្រប់គ្រាន់តើសាលាបានដោះស្រាយយ៉ាងដូចម្ដេច ចំពោះគរុសិស្ស ដែលគ្មានកន្លែងស្នាក់នៅ? ☐មិនបានដោះទេ ☐ប្រើថវិការដ្ឋជួលផ្ទះខាងក្រៅឱ្យពួកស្នាក់នៅ

២. តើការស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរបស់សាលា មានភាពងាយស្រួល និងការលំបាកយ៉ាងដូចម្ដេចដែរ?
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

៣.ក្នុងនាមអ្នកជាគរុសិស្ស តើអ្នកមានសំណូមអ្វីខ្លះដល់សាលាពាក់ព័ន្ធ នឹងអន្តេវា -សិកដ្ឋាននេះ?
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

*សូមអរគុណជាអនេកចំពោះ ការចំណាយពេលវេលាបំពេញកម្រងសំណួរទាំងនេះ !*